ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា ៧

# IMPORTANCE OF CAMBODIA INTERNATINAL ACCOUNTING STANDARDS (CIAS-7)

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា ៧

IMPORTANCE OF CAMBODIA INTERNATINAL ACCOUNTING STANDARDS (CIAS-7)

គ្រូណែនាំ៖ ឡេង កែវរតនៈ

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ សារៈសំខាន់នៃស្ពាន់ជាគណនេយ្យអន្តរជាតិកម្ពុជា ៧**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ឡេង កែវរតនៈ

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃនិងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យនៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ឆ្នាំរួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេសក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យគឺជាជំនាញមួយដែលមានសារៈសំខាន់សម្រាប់ទីផ្សារបច្ចុប្បន្នក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវការអនុវត្តគណនេយ្យដូចគ្នា។ដោយឡែកដើម្បីការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់សាកលវិទ្យាល័យវ៉ាន់ដាបានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងជំនាញគណនេយ្យហិរញ្ញវត្ថុនិងធនាគារតាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតយល់ច្បាស់ពីការអនុវត្តការងារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជា អនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងអ្នកស្រាវជ្រាវទាំងអស់យល់កាន់តែស៊ីជម្រៅពីការរៀបចំសារណានិងប្រសិទ្ធភាពនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា (លេខប្រាំពីរ)។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងសារណានេះហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីការរៀបចំលើកក្រោយទៀតកាន់តែមានភាពល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



ឈ្មោះ ម៉េង ស្រីពីន
ID: B22/831



ឈ្មោះ សែម សុវណ្ណនី
ID: B22/1167



ឈ្មោះ គី ណារីន
ID: B22/1191



ឈ្មោះ ហាក់ ស៊ូគាង
ID: B22/1192



ឈ្មោះ មៀច ស្រីម៉ី
ID: B22/1092

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **ឡេង កែវរតនៈ** ជាគ្រូណែនាំដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ"សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មី សុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ..៨កើត.. ខែ.កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ថ្ងៃទី.២៩. ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



ម៉េង ស្រីពិន

# សេចក្ដីសង្ខេបនៃការស្រាវជ្រាវ

នៅពេលបច្ចុប្បន្ន គ្រប់បណ្ដាប្រទេសទាំងអស់នៅសកលលោកមិនថា ប្រទេសកំពុងអភិវឌ្ឍន៍នោះទេ បែបបទនៃការគ្រប់គ្រងសេដ្ឋកិច្ច តែងតែមានការគ្រប់គ្រងខុសៗគ្នាទាំងអស់។ ការគ្រប់គ្រងហិរញ្ញវត្ថុ ក៏ជាកត្តាមួយដ៏សំខាន់ ក្នុងការអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចម្រើនដែរ។ បច្ចុប្បន្ននេះ រដ្ឋាភិបាលប្រទេសកម្ពុជាកំពុងតែមមាញឹក ក្នុងការអភិវឌ្ឍប្រព័ន្ធសេដ្ឋកិច្ចមិនថាតែវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម វិស័យហិរញ្ញនិងធនាគារ និងវិស័យផ្សេងៗទៀតឱ្យឈានដល់ចំណុចកំពូលដែលអាចស្តារសេដ្ឋកិច្ចឡើងវិញ ដោយជួយសម្រួល ដល់កិច្ចសហប្រតិបត្តិការជាមួយវិនិយោគិនបរទេសមកវិនិយោគក្នុងប្រទេសកម្ពុជា។ ទោះបីប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ក៏ពិតមែន ប៉ុន្តែមួយរយៈចុងក្រោយបានងើបមុខឡើងបន្តិចម្ដងៗ គួរឱ្យកត់សម្គាល់។

តាមរយៈការប្រមើលមើលទៅតាមតថភាពសង្គមជាក់ស្តែងប្រទេសកម្ពុជាបច្ចុប្បន្ននេះ ស្ថាប័នហិរញ្ញវត្ថុកំពុងតែមានការអភិវឌ្ឍឥតឈប់ឈរដូចនេះទើបក្រុមយើងខ្ញុំជ្រើសរើសយកប្រធានបទ "សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧ យកមកបកស្រាយនិងធ្វើការសិក្សាស្រាវជ្រាវ។ នៅក្នុងនោះយើងបានចោទជាចំណោទបញ្ហាចំនួន២ ដើម្បីយកមកធ្វើការបកស្រាយឱ្យកាន់តែស៊ីជម្រៅ អំពីរបាយការណ៍លំហូរសាច់ប្រាក់ទៅតាមតម្រូវការរបស់ស្ថាប័នរដ្ឋនិងស្ថាប័នឯកជន។ ក្នុងចំណោទបញ្ហាទីមួយនោះយើងនឹងបកស្រាយអំពីលំហូរសាច់ប្រាក់ចូល និងលំហូរសាច់ប្រាក់ចេញដែលកើតឡើងពាក់ព័ន្ធទៅនឹងសកម្មភាពរបស់អង្គភាពអាជីវកម្មនៅក្នុងអំឡុងពេលមួយ។ របាយការណ៍ហូរសាច់ប្រាក់ អាចផ្តល់លទ្ធភាពដល់អ្នកប្រើប្រាស់ទាំងឡាយវាយតម្លៃលើបម្រែបម្រួលនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាពរចនាសម្ព័ន្ធហិរញ្ញវត្ថុ( សន្ទនីយភាព និងសោធនភាព)។ ដើម្បីទ្រទ្រង់ដល់ដំណើរការរបស់ស្ថាប័នហិរញ្ញវត្ថុឱ្យបន្តទៅមុខដោយរលូននិងមានភាពរីកចម្រើនដោយការធានានូវសុវត្ថិ ភាពមិនមានការខាតបង់ដល់ស្ថាប័នធនាគារ។ ដោយឡែកចំណោទបញ្ហាទីពីរយើងនឹងធ្វើការបកស្រាយអំពីផលប្រយោជន៍របស់របាយការណ៍លំហូរសាច់ប្រាក់ទៅដល់អ្នកប្រើប្រាស់។

សរុបសេចក្តីមក ការស្រាវជ្រាវនេះនឹងធ្វើការបកស្រាយអំពីរបាយការណ៍លំហូរសាច់ប្រាក់ចូល និងលំហូរសាច់ប្រាក់ចេញរួមទាំងផ្តល់ព័ត៌មានស្តីពីបម្រែបម្រួលសាច់ប្រាក់ដើម និងសាច់ប្រាក់ប្រហាក់ប្រហែលរបស់អង្គភាពមួយទៅតាមរយៈរបាយការណ៍លំហូរសាច់ប្រាក់ ដោយធ្វើចំណាត់ថ្នាក់លំហូរសាច់ប្រាក់ ក្នុងការិយបរិច្ឆេទទៅតាមសកម្មភាពប្រតិបត្តិការ សកម្មភាវិនិយោគនិងសកម្មភាពហិរញ្ញប្បទាន។ មួយវិញទៀតថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និងបុគ្គលិកសុទ្ធតែមានជំនាញនិងមានចំណេះដឹងគ្រប់គ្រាន់ព្រមទាំងមានភាពច្បាស់លាស់ក្នុងការធ្វើរបាយការណ៍ ការព្យាករណ៍ និងរៀបចំផែនការហិរញ្ញវត្ថុឱ្យដំណើរការយ៉ាងរលូនមានលក្ខណៈជាក់លាក់និងឱ្យមានប្រសិទ្ធភាពខ្ពស់។

# មាតិកា

ទំព័រ


អារម្ភកថា ........................................ i

រចនាសម្ព័ន្ធ ........................................ ii

សេចក្ដីថ្លែងអំណរគុណ ........................................ iii

អំណះអំណាង ........................................ iv

សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ........................................ v

មាតិកា ........................................ vi

## ជំពូកទី១
## សេចក្ដីផ្ដើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ២

១. តើអ្វីជាគោលបំណងរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ?

២. តើរបាយការណ៍លំហូរសាច់ប្រាក់មានផលប្រយោជន៍អ្វីខ្លះដល់អ្នកប្រើប្រាស់ ?

១.៣ គោលបំណងនៃការស្រាវជ្រាវ ........................................ ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........................................ ២

១.៤.១ ទំហំដែនកំណត់ ........................................ ២

១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........................................ ៣

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................ ៣

១.៥.១ បកស្រាយតាមសំណួរទី១ ........................................ ៣

១.៥.២ បកស្រាយតាមសំណួរទី២ ........................................ ៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........................................ ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៤

## ជំពូកទី២
## សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា ៧

២.១ លក្ខណៈទូទៅនៃសារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា ........................................ ៥

២.១.១ និយមន័យស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា ........................................ ៥

២.១.២ ប្រវត្តិនៃស្តង់ដាគណនេយ្យ ........................................ ៥

២.១.៣ ចំណាត់ថ្នាក់គណនេយ្យ ........................................ ៥

២.២ គោលបំណងរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ........................................ ៦

២.២.១ និយមន័យ ........................................ ៦

២.២.២ ប្រវត្តិស្តង់ដាគណនេយ្យ ........................................ ៧

២.២.៣ ទ្រឹស្ដីពាក់ព័ន្ធស្តង់ដាគណនេយ្យអន្តរជាតិ ........................................ ៩

២.៣ ផលប្រយោជន៍នៃការប្រើប្រាស់ស្តង់ដាគណនេយ្យ ........................................ ៩
២.៣.១ ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ........................................ ៩
២.៣.២ ទ្រឹស្តីនៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧ ........................................ ១០

## ជំពូកទី៣

## សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា ៧

៣.១ ស្ថានភាពទូទៅនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា៧ ........................................ ១១
៣.១.១ ប្រវត្តិរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា៧ ........................................ ១១
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ........................................ ១២
ក.ចក្ខុវិស័យ ........................................ ១២
ខ.បេសកកម្ម ........................................ ១៣
គ.គោលដៅ ........................................ ១៤
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រងតួនាទីនឹងភារកិច្ចរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ........................................ ១៤
ក. រចនាសម្ព័ន្ធគ្រប់គ្រង ........................................ ១៤
ខ. តួនាទីគណគ្រប់គ្រង ........................................ ១៥
៣.២ គោលបំណងរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ........................................ ១៥
៣.២.១ ការប្រើប្រាស់របាយការណ៍លំហូរសាច់ប្រាក់ ........................................ ១៥
៣.២.២ ការរាយការណ៍អំពីលំហូរសាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងហិរញ្ញប្បទាន ........................................ ១៨
៣.២.៣ ការរាយការណ៍អំពីលំហូរសាច់ប្រាក់តាមមូលដ្ឋានពិត ........................................ ១៩
៣.២.៤ធាតុពិសេស ការប្រាក់និងភាគលាភរបស់របាយការណ៍លំហូរសាច់ប្រាក់ ........................................ ១៩
៣.៣ ផលប្រយោជន៍នៃការប្រើប្រាស់របាយការណ៍លំហូរសាច់ប្រាក់ ........................................ ២១
៣.៣.១ ផលប្រយោជន៍នៃការប្រើប្រាស់របាយការណ៍លំហូរសាច់ប្រាក់ ........................................ ២១
៣.៣.២ ការកាត់បន្ថយហានិភ័យផ្ទៃក្នុង ........................................ ២២

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ការវិភាគលើចំណុចខ្លាំង ........................................ ២៣
៤.២ ការវិភាគលើចំណុចខ្សោយ ........................................ ២៤

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................ ២៥
៥.២ ការផ្តល់អនុសាសន៍ ........................................ ២៥
**ឯកសារយោង**
**ឧបសម្ព័ន**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ជាទូទៅទន្ទឹមនឹងការរីកចម្រើននៃសេដ្ឋកិច្ចពិភពលោកប្រទេសនីមួយៗបានខិតខំប្រឹងប្រែងអភិវឌ្ឍន៍ខ្លួនឯងលើគ្រប់វិស័យ មានដូចជាវិស័យអប់រំ វិស័យទេសចរណ៍ វិស័យសេដ្ឋកិច្ច វិស័យវាយនភណ្ឌ វិស័យហិរញ្ញវត្ថុ ដែលក្នុងនោះក៏ឃើញថាវិស័យអប់រំបានរីកដុះដាលជាខ្លាំងទៅលើគ្រប់ជំនាញមានដូចជា ជំនាញគណនេយ្យ ជំនាញហិរញ្ញវត្ថុ ជំនាញគ្រប់គ្រង ជំនាញសេដ្ឋកិច្ច ដែលសុទ្ធតែជាជំនាញមួយដែលមាននិស្សិត សិក្សាច្រើនជាងគេនៅតាមសកលវិទ្យាល័យ ឬមហាវិទ្យាល័យ។ ទន្ទឹមនឹងនេះគោលនយោបាយបើកចំហទូលាយនៅប្រព័ន្ធទីផ្សារសេរីដែលមានភាពចាំបាច់ទៅលើស្តង់ដាគណនេយ្យ គឺមានសារៈសំខាន់ខ្លាំងសម្រាប់សេដ្ឋកិច្ចដែលកំពុងរីកលូតលាស់នៅក្នុងប្រទេសកម្ពុជាត្រូវបានគេមើលឃើញថាជាក្បាលម៉ាស៊ីនដ៏សំខាន់ដើម្បីជំរុញសេដ្ឋកិច្ចឆ្ពោះទៅមុខក្លាយទៅជាប្រទេសអភិឌ្ឍន៍។ ដើម្បីសម្រេចបានសមិទ្ធផលនេះព្រះរាជាណាចក្រកម្ពុជាត្រូវការគណនេយ្យករជំនាញដើម្បីធានាថាសហគមន៍ធុរកិច្ចគោរពតាមបទដ្ឋាន និងបទប្បញ្ញត្តិអន្តរជាតិ។ គណនេយ្យករអាជីពសព្វថ្ងៃមានការពេញនិយម និងតម្រូវការខ្ពស់ ចំណេះដឹង និងជំនាញដែលទទួលបានក្នុងការបណ្តុះបណ្តាលនិងមានប្រយោជន៍ក្នុងជីវិតរបស់ប្រជាពលរដ្ឋគ្រប់រូបនៃប្រទេសកម្ពុជា។ សព្វថ្ងៃយើងក៏សង្កេតឃើញថាសារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧ ក៏ជាព័ត៌មានស្តីអំពីលំហូរសាច់ប្រាក់នៃអង្គភាពមានសារៈប្រយោជន៍ក្នុងការផ្តល់ឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ នូវមូលដ្ឋានសម្រាប់វាយតម្លៃនៃលទ្ធភាពរបស់អង្គភាព ក្នុងការបង្កើតសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល និងសម្រាប់វាយតម្លៃការប្រើប្រាស់លំហូរសាច់ប្រាក់ទាំងនោះ។ សេចក្តីវិនិច្ឆ័យតាមបែបសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ទាំងឡាយលទ្ធភាពរបស់អង្គភាពមួយក្នុងការបង្កើតសាច់ប្រាក់និងសាច់ប្រាក់ប្រហាក់ប្រហែលនិងការកំណត់ពេលវេលានិងភាពប្រាកដប្រជានៃការបង្កើតសាច់ប្រាក់របស់អង្គភាពនានាដើម្បីប្រើប្រាស់ជាជំនួយដ៏ល្អប្រសើរបំផុតសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត។ មួយវិញទៀតការជ្រើសរើសថ្នាក់សិក្សានូវមហាវិទ្យាល័យដូចជា ជំនាញគណនេយ្យពិតជាសំខាន់ណាស់ដោយសារវាជួយមនុស្សគ្រប់គ្នាយល់ដឹងពីស្តង់ដាគណនេយ្យដែលរួមផ្សំនូវឱកាសការងារជាច្រើនបន្ថែមទៀត។

តួយ៉ាងដូចជានៅប្រទេសកម្ពុជាការអប់រំអំពីស្តង់ដាគណនេយ្យមានច្រើនដូចជា តាមមហាវិទ្យាល័យ, វិទ្យាស្ថានគឺសុទ្ធសឹងតែមាននូវការអប់រំមុខជំនាញគណនេយ្យសម្រាប់និស្សិតជ្រើសរើសយកមកសិក្សាដើម្បីក្លាយជាគណនេយ្យករជំនាញមួយដែលមានទំនួលខុសត្រូវជាចម្បងលើតំណែងមួយនេះដើម្បីធ្វើការវិភាគ,ការកត់ត្រាទិន្នន័យនៃរបាយការណ៍លំហូរសាច់ប្រាក់។ ម្យ៉ាងវិញទៀតការអនុវត្តន៍ស្តង់ដាគណនេយ្យគឺបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់រាជរដ្ឋាភិបាលនិងសាធារណជននៅក្នុងការគ្រប់គ្រងទ្រព្យសកម្ម បំណុលនិងបំណុលជាយថាហេតុនានារបស់អង្គភាព។ដើម្បីបង្កើននូវតម្លាភាព គណនេយ្យភាព ភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើឱ្យមានភាពងាយស្រួលក្នុងការម្រេចចិត្តរបស់អង្គភាពដើម្បីបង្កើននូវប្រសិទ្ធភាពនៃការរាយការណ៍អាចប្រៀបធៀបគ្នាបានជាអន្តរជាតិនៃរបាយការណ៍ហិរញ្ញវត្ថុ។

ដូច្នេះអង្គភាព សហគ្រាស ស្ថាប័នជាតិ ស្ថាប័នអន្តរជាតិ និងអាជីវកម្ម គឺសុទ្ធសឹងតែត្រូវការផ្នែកគណនេយ្យដើម្បីកត់ត្រាប្រតិបត្តិការសេរុបតួលេខ វិភាគទិន្នន័យចំណូល ចំណាយ និងសម្រាប់ធ្វើរបាយការណ៍ផ្សេងៗដែលពាក់ព័ន្ធនឹងស្ថាប័នរបស់ខ្លួន។ ស្តង់ដាគណនេយ្យគឺជាគ្រឹះដ៏សំខាន់និងជាចម្បងសម្រាប់សេដ្ឋកិច្ចជាតិ អន្តរជាតិ ស្ថាប័នរដ្ឋ និងឯកជនសម្រាប់ទ្រទ្រង់រាល់ប្រតិបត្តិការព្រមទាំងចាំជួយដោះស្រាយរាល់បញ្ហាគ្រប់ស្ថាប័នមិនអាចខ្វះបានដែលទាក់ទងនឹងហិរញ្ញវត្ថុដើម្បីមានភាពងាយស្រួលស្វែងរកភាពរីកចម្រើនឬអន់ថយរបស់សេដ្ឋកិច្ចនិងស្ថាប័ននានានាពេលបច្ចុប្បន្ននិងនាពេលអនាគត។ ដោយសារតែឃើញពីអត្ថប្រយោជន៍និងសារៈសំខាន់បែបនេះហើយទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទស្តីពី៖ "**សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧**" យកមកសិក្សាស្រាវជ្រាវនិងចងក្រងជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដែលទាក់ទងទៅនឹងស្តង់ដាគណនេយ្យ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាស្តង់ដាគណនេយ្យមានសារៈសំខាន់ខ្លាំងសម្រាប់សេដ្ឋកិច្ចដែលកំពុងរីកលូតលាស់របស់កម្ពុជា ខណៈដែលវិស័យធុរកិច្ចរបស់ប្រទេសកម្ពុជា ត្រូវបានគេមើលឃើញថាជាក្បាលម៉ាស៊ីនដ៏សំខាន់ដើម្បីជំរុញសេដ្ឋកិច្ចឆ្ពោះទៅមុខនិងធ្វើក្លាយទៅជាប្រទេសអភិវឌ្ឍន៍។ អាស្រ័យហេតុដូច្នេះហើយបានជាយើងចាំបាច់ត្រូវសិក្សាពីស្តង់ដាគណនេយ្យដើម្បីជួយអភិវឌ្ឍន៍នូវសេដ្ឋកិច្ចប្រទេសកម្ពុជារីកចម្រើនជាលំដាប់។ ដើម្បីជាទុននិងជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងអំពីទិដ្ឋភាពទូទៅជុំវិញនៃប្រធានបទអត្ថប្រយោជន៍នៃការសិក្សាស្តង់ដាគណនេយ្យយើងគួរគប្បីស្វែងយល់អំពីពាក្យគន្លឹះ និងសំណួរមួយចំនួនខាងក្រោមជាមុនសិន។

១. តើអ្វីជាគោលបំណងរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ?

២. តើរបាយការណ៍លំហូរសាច់ប្រាក់មានផលប្រយោជន៍អ្វីខ្លះដល់អ្នកប្រើប្រាស់ ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងនៃការសិក្សាស្រាវជ្រាវនេះគឺដើម្បីស្វែងយល់អំពីអត្ថប្រយោជន៍នៃការសិក្សាស្តង់ដាគណនេយ្យរួមមាន៖

- ការសិក្សាពីអត្ថប្រយោជន៍នៃការផ្តល់ព័ន៍មានអំពីចលនាសាច់ប្រាក់
- ជួយដល់ការធ្វើសេចក្តីសន្និដ្ឋានអំពីស្ថានភាពហិរញ្ញវត្ថុ
- ស្វែងយល់អំពីការបែងចែកប្រភេទនៃចលនាសាច់ប្រាក់
- យល់ដឹងអំពីស្ថានភាពទូទៅនៃតម្រូវការស្តង់ដាគណនេយ្យ
- បង្កើនការយល់ដឹងពីការគ្រប់គ្រងហិរញ្ញវត្ថុ។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែនកំណត់

ក្នុងការសិក្សាស្រាវជ្រាវនេះមានប្រសិទ្ធភាពផ្តោតសំខាន់ទៅលើប្រធានបទ "**សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧**"ដកស្រង់ចេញពីក្រុមប្រឹក្សាជាតិគណនេយ្យ ដែលមានទីតាំងនៅផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាព

ទិន្នន័យដែលលើកយកមកបង្ហាញនៅក្នុងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលបានមកពីប្រព័ន្ធគេហទំព័រ ក្នុងឆ្នាំ២០២១ ក្រុមប្រឹក្សាជាតិគណនេយ្យ ព្រមទាំងឯកសារពីបណ្ណាល័យនៃសាកលវិទ្យាល័យវ៉ាន់ដា។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវ បានប្រើប្រាស់តាមវិធីសាស្ត្រគុណវិស័យដោយផ្តោតចម្បងទៅលើការវិភាគ ការកត់ត្រាទិន្នន័យនៃរបាយការណ៍លំហូរសាច់ប្រាក់ព្រមទាំងជាគ្រឹះដ៏សំខាន់សម្រាប់ សេដ្ឋកិច្ចជាតិ អន្តរជាតិ ស្ថាប័នរដ្ឋ និងឯកជនសម្រាប់ទ្រទ្រង់រាល់ប្រតិបត្តិការព្រមទាំងចាំជួយដោះស្រាយរាល់បញ្ហាគ្រប់ស្ថាប័នមិនអាចខ្វះបានដែលទាក់ទងនឹងហិរញ្ញវត្ថុដើម្បីមានភាពងាយស្រួលស្វែងរកភាពរីកចម្រើន ឬអន់ថយរបស់សេដ្ឋកិច្ចនិងស្ថាប័ននានានាពេលបច្ចុប្បន្ននិងនាពេលអនាគត។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដូចជាការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័របណ្តាញសង្គមរបស់ស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗ បានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវឯកសារមេរៀនទាំងឡាយណា ដែលពាក់ព័ន្ធនឹងប្រធានបទការអានកម្រងឯកសារផ្សេងៗ របាយការណ៍ដែលយកចេញពីអ៊ីនធឺណេត និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដូចជាការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័របណ្តាញសង្គមរបស់ស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវឯកសារមេរៀនទាំងឡាយណា ដែលពាក់ព័ន្ធនឹងប្រធានបទការអានកម្រងឯកសារផ្សេងៗ របាយការណ៍ចាស់ៗ ដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ពិតជាផ្តល់សារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើនជាពិសេសចំពោះ៖

### ១.៦.១ ចំពោះក្រុមអ្នកស្រាវជ្រាវផ្ទាល់

- ជួយបង្កើនចំណេះដឹងជំនាញ សមត្ថភាពផ្ទាល់ខ្លួន ដោយការផ្សាភ្ជាប់រវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែង
- យល់ដឹងកាន់តែច្បាស់អំពីស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧
- យល់ដឹងពីគោលនយោបាយ និងនីតិវិធីរៀបចំផែនការ ការធ្វើសវនកម្មផ្ទៃក្នុងនិងការរៀបចំអំពីរបាយការណ៍លំហូរសាច់ប្រាក់ ដែលចំណេះដឹងទាំងនេះអាចជាស្ពានសម្រាប់យើងក្នុងការស្វែងរកឱកាសការងារ
- ចេះធ្វើការងារជាក្រុម និងចេះសម្របសម្រួលដោះស្រាយបញ្ហាក្នុងក្រុម
- ពង្រឹងបន្ថែមលើទំនួលខុសត្រូវលើកិច្ចការស្រាវជ្រាវ

### ១.៦.២ ចំពោះស្ថាប័ន

- ការពង្រឹងភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ

- ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព
- ការអភិវឌ្ឍន៍ការចំណាយ និងចំណូល
- ការអនុវត្តផែនការ និងយុទ្ធសាស្រ្ត
- ការអនុវត្តលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តិ ។

**១.៦.៣ ចំពោះសង្គម**

- បានផ្សព្វផ្សាយពីចំណេះដឹងទៅដល់និស្សិតជំនាន់ក្រោយ
- ចងក្រងជាឯកសារសម្រាប់សិស្សប្អូនធ្វើការសិក្សាស្រាវជ្រាវបន្ត
- ជួយជានាប្រព័ន្ធហិរញ្ញវត្ថុមានស្ថេរភាព និងលើកកម្ពស់ការវិនិយោគ
- ជួយកាត់បន្ថយការមិនប្រកបដោយសុចរិតភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**ជំពូកទី១ សេចក្តីផ្តើម៖** ជំពូកនេះ បានបង្ហាញពីលំនាំដើមបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវវិធីសាស្រ្តនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវរចនាសម្ពន្ធ័ការស្រាវជ្រាវ

**ជំពូកទី២ ការពិនិត្យមើលឡើងវិញ៖**ជំពូកនេះ បានលើកឡើងអំពីលក្ខណៈទូទៅនៃស្តង់ដាគណនេយ្យកម្ពុជា ៧។

**ជំពូកទី៣ លទ្ធផលនៃការស្រាវជ្រាវ៖** គឺបង្ហាញអំពីស្ថានភាពទូទៅនៃរបាយការណ៍លំហូរសាច់ប្រាក់ដូចជា ចក្ខុវិស័យ បេសកកម្ម រចនាសម្ព័ន្ធចាត់តាំងនៃស្តង់ដាគណនេយ្យកម្ពុជា ៧ តួនាទីផលប្រយោជន៍ និងដំណើរការផ្សេងៗទៀតនៃស្តង់ដាគណនេយ្យ

**ជំពូកទី៤ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ៖** ក្នុងជំពូកនេះ គឺវិភាគទៅលើចំណុចដែលបានអនុវត្តជាក់ស្តែងក្នុងគោលបំណងវិភាគឱ្យឃើញនូវចំណុចខ្លាំង និងចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើការកែលម្អបន្ថែមទៀត

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍៖** ធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ និងផ្តល់យោបល់ជាអនុសាសន៍ទៅលើចំណុចដែលត្រូវកែលម្អបន្ថែមទៀត។

# ជំពូកទី២
# សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា

## ២.១ លក្ខណៈទូទៅនៃសារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា

### ២.១.១ និយមន័យស្តង់ដាគណនេយ្យកម្ពុជា

គណនេយ្យ គឺជាសកម្មភាពសេវាមួយ។ មុខងាររបស់វាគឺផ្តល់នូវទិន្នន័យ (ដែលមានលក្ខណៈជាហិរញ្ញវត្ថុ)ស្តីពីសកម្មភាពសេដ្ឋកិច្ចរបស់អង្គភាពអាជីវកម្មក្នុងគោលបំណងប្រើប្រាស់ទិន្នន័យនោះ ផ្តល់ទៅឱ្យអ្នកប្រើប្រាស់(Users) ធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចសមស្របមួយ។

### ២.១.២ ប្រវត្តិនៃគណនេយ្យ

នៅក្នុងឆ្នាំ១០៦៦ ក្នុងជំនាន់ព្រះអង្គម្ចាស់ក្សត្រី Elizabeth Ⅱ មានមេទ័ពមួយឈ្មោះថា William គឺជាអ្នកចំបាំងមួយដ៏ពូកែ ហើយបានប្រមូលកុលសម្ព័ន្ធពួក Anglo-Saxon បង្កើតជាចក្រភពអង់គ្លេស។ បន្ទាប់ពីវាយឈ្នះលើកុលសម្ព័ន្ធនោះរួចហើយ មេទ័ពនោះត្រូវបានព្រះអង្គម្ចាស់ក្សត្រីឱ្យដើរុករានទន្រ្ទាន ដើម្បីរាប់មើល និងវាយតម្លៃ ដូចជា ដី ធនធានធម្មជាតិ មនុស្ស និងសត្វពាហណៈទាំងអស់ ទោះជារបស់រដ្ឋក្តី ទោះជារបស់ប្រជាពលរដ្ឋក្តី ។

បន្ទាប់មក William ក៏បានចាប់ផ្តើមគណនាពីបំណុល ទាំងបំណុលក្នុងប្រទេស និងជាមួយបរទេសទៀត។ ពេលនោះ William រកឃើញពីភាពខុសគ្នារវាងទ្រព្យសម្បត្តិរបស់ព្រះអង្គម្ចាស់ក្សត្រី (របស់ជាតិអង់គ្លេស) និង បំណុលរបស់ព្រះអង្គម្ចាស់ក្សត្រី ដែលជំពាក់គេវិញ។ ភាពខុសគ្នានេះ គេឱ្យឈ្មោះហៅថា ទ្រព្យសម្បត្តិពិតរបស់ព្រះអង្គម្ចាស់ក្សត្រី ។

Owner's Equity = Assets - Liabilities

ទុនរបស់ក្រុមហ៊ុន = ទ្រព្យសកម្ម - បំណុល

ពេល William ចេញធ្វើប្រតិបត្តិការ ដើរុករានទន្រ្ទានក្នុងទឹកដី Anglo-Saxon ទាំងមូលធ្វើឱ្យប្រជាពលរដ្ឋមានការភ័យព្រួយយ៉ាងខ្លាំង ។

កិច្ចការខាងលើនេះ គឺ William បានធ្វើទាល់តែសម្រេច រួចក៏ចងក្រងសៀវភៅមួយនៅក្នុងឆ្នាំ១០៨៦។ សៀវភៅនោះមានឈ្មោះថា Domesday Book ។

បច្ចុប្បន្ន គណនេយ្យដែលយើងរៀននេះ មានប្រភពដើមពីគណនេយ្យ Anglo-Saxon ដែលដឹកនាំដោយប្រទេសពីរគឺ British & American Green Intermediate in liabrary

### ២.១.៣ ចំណាត់ថ្នាក់គណនេយ្យ

ចំណាត់ថ្នាក់គណនេយ្យមាន៣គឺ

1-គណនេយ្យហិរញ្ញវត្ថុ (Financial Accounting) គឺជាមុខវិជ្ជាគណនេយ្យសម្រាប់អ្នកប្រើប្រាស់ខាងក្រៅ។

2-គណនេយ្យគ្រប់គ្រង (Management Accounting) មុខវិជ្ជាគណនេយ្យសម្រាប់អ្នកប្រើប្រាស់ខាងក្នុង( សម្រាប់អ្នកគ្រប់គ្រង )។

3-សវនកម្ម (Auditing) គឺជាសេវាមួយបែប ដែលធ្វើការវាយតម្លៃលើរបាយការណ៍ហិរញ្ញវត្ថុដែលអះអាងដោយអ្នកគ្រប់គ្រង និងបញ្ចេញមតិយោបល់[1]។

## ២.២ គោលបំណងរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

### ២.២.១ និយមន័យ

ស្តង់ដាគណនេយ្យ គឺជាសំណុំបទដ្ឋាននិងវិធានការដែលកំណត់វិធីសាស្ត្រ និងលក្ខណៈវិជ្ជមានសម្រាប់ការរៀបចំ ឬបង្ហាញព័ត៌មានហិរញ្ញវត្ថុ។ ស្តង់ដាគណនេយ្យមានសារៈសំខាន់ចំបងក្នុងការធានាថាព័ត៌មានហិរញ្ញវត្ថុដែលបង្ហាញដោយស្ថាប័នឬអាជីវកម្ម មានភាពអាចទុកចិត្តបាន មានភាពស្វែងយល់បានធ្វើការប្រៀបធៀបបាន និងមានការគោរពតាមបទដ្ឋានសកល។

- គោលនយោបាយនៃលំហូរសាច់ប្រាក់

ពត៌មានស្តីអំពីលំហូរសាច់ប្រាក់នៃអង្គភាពមានសារប្រយោជន៍ក្នុងការផ្តល់ឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនូវមូលដ្ឋានសម្រាប់ការវាយតម្លៃនៃលទ្ធភាពរបស់អង្គភាពក្នុងការបង្កើតសាច់ប្រាក់និងសាច់ប្រាក់ប្រហាក់ប្រហែលនិងសម្រាប់វាយតម្លៃពីតំរូវការប្រើប្រាស់លំហូរសាច់ប្រាស់ទាំងនោះ។សេចក្តីវិនិច្ឆ័យតាមបែបសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ទាំងឡាយលទ្ធរបស់អង្គភាពមួយក្នុងការបង្កើតសាច់ប្រាក់និងសាច់ប្រាស់ប្រហាក់ប្រហែលនិងការកំណត់ពេលវេលានិងភាពប្រាកដប្រជានៃការបង្កើតសាច់ប្រាក់4.5របស់អង្គភាព។

- សារៈសំខាន់នៃលំហូរសាច់ប្រាក់

របាយការណ៍លំហូរសាច់ប្រាក់មួយនៅពេលដែលវាត្រូវបានប្រើប្រាស់រួមជាមួយរបាយការណ៍ផ្សេងៗទៀតនៃរបាយការណ៍ហិរញ្ញវត្ថុនោះផ្តល់ព័តមានដែលអាចផ្តល់លទ្ធភាពដល់អ្នកប្រើប្រាស់ទាំងឡាយក្នុងការវាយតម្លៃលើបំរែបំរួលនៃទ្រព្យសកម្មសុទ្ធនៃអង្គភាព រចនាសម្ពន្ធ័ហិរញ្ញវត្ថុ របស់អង្គភាព។ របាយការណ៍នេះក៏ជួយធ្វើអោយការប្រៀបធៀបមានភាពប្រសើរឡើង នៃការធ្វើរបាយការណ៍ដោយអង្គភាពផ្សេងៗ ចំពោះការអនុវត្តន៍ប្រតិបត្តិការណ៍ ពីព្រោះវាបានលុបបំបាត់ចោល នូវផលប៉ះពាល់ដោយសារការប្រើប្រាស់ការធ្វើគណនេយ្យកម្មខុសៗគ្នា។

១.ការប្រៀបធៀបបាន ស្តង់ដាគណនេយ្យអនុញ្ញាតអាជីវកម្មនានា អាចប្រៀបធៀបទិន្នន័យហិរញ្ញវត្ថុរបស់ពួកគេបាន។

២. ភាពអាចទុកចិត្តបាន ជួយធ្វើអ្នកទាំងអស់មានទំនុកចិត្តលើព័ត៌មានហិរញ្ញវត្ថុដែលបានចេញផ្សាយ។

៣. ការគោរពបទដ្ឋានអន្តរជាតិ ជួយអាជីវកម្មឬស្ថាប័នអាចប្រតិបត្តិការក្នុងកម្រិតអន្តរជាតិដោយមានលក្ខណៈស្តង់ដា។

៤. ការសម្រេចចិត្តល្អ ជួយដល់អ្នកគ្រប់គ្រង អ្នកវិនិយោគ និងអាជីវកម្មដើម្បីធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើទិន្នន័យត្រឹមត្រូវ។

៥.ការរួមចំណែកក្នុងការគ្រប់គ្រងហានិភ័យ ផ្តល់លក្ខណៈច្បាស់លាស់ក្នុងការបង្ហាញហានិភ័យហិរញ្ញវត្ថុរបស់អាជីវកម្ម។

[1] សាកលវិទ្យាល័យវ៉ាន់ដា. (២០១៩). *Financial Reporting & Accounting Standard*. បោះពុម្ពលើកទី១១. ភាគ៣ ទំព័រទី៣

គោលនយោបាយនៃស្តង់ដាគណនេយ្យ អាចត្រូវបានកំណត់ដោយអង្គភាពដូចជា International Financial Reporting Standards (IFRS) និង Generally Accepted Accounting Principles (GAAP) ដែលជាស្ថាប័នគ្រប់គ្រងស្តង់ដាគណនេយ្យ។

អង្គភាពអាជីវកម្មត្រូវការគណនេយ្យ ព្រោះវាមានសារៈសំខាន់ណាស់ដូចជា ៖

- អាចជួយក្នុងការរៀបចំបញ្ជីផ្សេងៗរបស់ក្រុមហ៊ុនឱ្យមានរបៀបរៀបរយ
- បង្កើតពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដើម្បីឱ្យអ្នកគ្រប់គ្រង ឬម្ចាស់ក្រុមហ៊ុនងាយស្រួលក្នុងការរៀបចំយុទ្ធសាស្រ្ត និងចេញសេចក្តីសម្រេចផ្សេងៗ
- បង្កើតពីស្ថានភាពចំណូលនិងចំណាយ ដែលបានកើតឡើងក្នុងដំណើការអាជីវកម្ម ដែលអាចឱ្យអ្នកគ្រប់គ្រងមានលទ្ធភាពក្នុងការកាត់បន្ថយទៅលើចំណាយមួយចំនួនដែលមិនចាំបាច់
- គណនេយ្យ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ធ្វើការវិភាគពិចារណាលើគោលការណ៍ ផែនការ និងការកំណត់ទិសដៅផ្សេងៗទៀត
- បង្កើតលទ្ធភាពនៃការសងបំណុលរបស់ក្រុមហ៊ុន
- បង្កើតលទ្ធភាពនៃការធ្វើអាជីវកម្ម ថាតើចំណេញឬខាត
- វាអាចកាត់បន្ថយការកេងប្រវ័ញ្ចផ្សេងៗបាន
- សម្រាប់ជាភ្នាក់ងាររបស់រដ្ឋាភិបាល ក្នុងការកំណត់មុខងារហិរញ្ញវត្ថុ អាជីវកម្មសម្រាប់បង់ពន្ធ និងរៀបចំថវិកាជាតិ ។

### ២.២.២ ប្រវត្តិស្តង់ដាគណនេយ្យ

កាលពីដើមរាប់រយឆ្នាំមុន (នៅសហរដ្ឋអាមេរិចមាន 51រដ្ឋ) ក្នុងមួយរដ្ឋៗ ដែលអនុវត្តគណនេយ្យតាមរបៀបផ្ទាល់ៗខ្លួន។ ជួនកាលទៅជួលក្រុមហ៊ុនអាជីពគណនេយ្យដែលក្រុមហ៊ុននោះដំឡើងរបាយការណ៍ហិរញ្ញវត្ថុខុសៗគ្នាទៀត។ នៅក្នុងឆ្នាំ 1929 វិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរក៏ផ្ទុះឡើងដោយសាររបាយការណ៍ហិរញ្ញវត្ថុខុសៗគ្នា(គ្មានឯកលក្ខណៈភាព) គ្មានច្បាប់គ្រប់គ្រងផ្សារលក់ហ៊ុន (គ្មានSEC)។

-ដោយយល់ឃើញដូច្នេះ អ្នកដែលមានអាជីពជាគណនេយ្យបានកោះហៅគ្នាមកប្រជុំ រួមមានពាណិជ្ជករ អ្នកសិក្សាស្រាវជ្រាវ SECC និង Tax មកប្រជុំកំណត់ស្តង់ដា។

-ក្រោយពីបានប្រជុំរួច អ្នកទាំងនោះក៏សម្រេចកំណត់បានជាស្តង់ដា។ ស្តង់ដានេះបានកំណត់ជា GAAP របស់សហរដ្ឋអាមេរិច (Generally Accepted Accounting Principle) គឺជាស្តង់ដាដែលកំពុងប្រើប្រាស់សព្វថ្ងៃនេះ។

-ដើម្បីធ្វើការបោះពុម្ពផ្សាយនិងកំណត់ស្តង់ដា គណៈកម្មាធិការដំបូងមួយត្រូវបានបង្កើតឡើងមុនគេនៅសហរដ្ឋអាមេរិច មានឈ្មោះហៅថា CAP ក្នុងឆ្នាំ1939។

-CAP (Committee on Accounting Procedure)

-Born 1939-1959 (American Institute of Certifies Public Accountant)

-អ្នកបង្កើត CAP គឺ AICPA។ CAP មានតួនាទីបង្កើតស្តង់ដាគណនេយ្យក្នុងគោលបំណងមួយឱ្យមានលក្ខណៈជាតិ។ ក្រោយមក CAP លែងស្តាប់ AICPA។ ធ្វើការស្រេចតែចិត្ត។ AICPA ក៏រំលាយចោល ដោយបង្កើតគណៈកម្មាធិការថ្មីមួយទៀត ដែលឱ្យឈ្មោះថា APB (Accounting Principal Board) ។

-Born (1959 - 1973) មានមុខងារដូច CAP ដែរ។តែក្រោយមកធ្វើឱ្យបាត់បង់ការទុកចិត្តពីAICPAទៀត។ ហើយក្រុមហ៊ុន Audit ចូលរួមធ្វើការប្រឆាំង។ APB ក៏ត្រូវរំលាយដូច CAP ដែរនៅក្នុងឆ្នាំ1973។

-FASB (Financial Accounting Standard Board)

-Born 1973

-Pronouncement = Statement of Financial Accounting Standard Boards

-Has the seven full time members, 5 member's part time draw from professional accounting government, Business, and academic.

-The fund 1/3 from accounting professional and business, and 2/3 from sale of publication and services, funded 20 million yearly.

-Is the private sector.

- 5 years life limited, to be selected (member).

-International Accounting Standard (IAS)

1-IASC: (International Accounting Standard Committee)

. IASC កើតឡើងក្នុងឆ្នាំ1973 ( ទន្ទឹមនឹង FASB ) បង្កើតដោយ Accounting Professional ពី 10 ប្រទេស។ ហើយបានប្តូរទៅជា IASB។ សព្វថ្ងៃ IASB មានសមាជិក 140 ក្រុមមកពី 100 ប្រទេសក្នុងពិភពលោក ទីស្នាក់ការធំរបស់ IASB គឺនៅទីក្រុង London។

2-IASB: (International Accounting Standard Board) មានភារកិច្ចកំណត់ស្តង់ដាគណនេយ្យ ហើយត្រូវការសម្លេង 8/14 ដើម្បីអនុម័ត។ សមាជិកអចិន្ត្រៃយ៍ធ្វើការពេញម៉ោង 12 នាក់ និង Part Time 2 នាក់។

3-IAS: (International Accounting Standard)

. IASB គឺជាអ្នកកំណត់ស្តង់ដាសម្រាប់ពិភពលោកប្រើ ដែលស្តង់ដានោះគេឱ្យឈ្មោះហៅថា IAS។

. សព្វថ្ងៃ IASB បានកំណត់ 41 Standard និង IFRS 17

4-CAS: (Cambodia Accounting Standard)

4.1- ឯកឧត្តម ងី តាយី សហការជាមួយ Price Waterhouse ក្រោមប្រាក់កម្ចី World Bank បានបង្កើតច្បាប់គណនេយ្យនៅកម្ពុជា។ អនុវត្តនៅថ្ងៃទី 28/05/02។

4.2- NAC: (National Accounting Council) ក្រុមប្រឹក្សាជាតិគណនេយ្យ។

. NAC ជាអ្នកកំណត់ Accounting Standard នៅកម្ពុជា។ NAC បង្កើតឡើងនៅថ្ងៃ 03/03/03 តាមប្រកាស លេខ 170 សហវ 27/03/03 ។

4.3- Cambodia Accounting Standard (CAS) ស្តង់ដាគណនេយ្យកម្ពុជាមាន 15 ស្តង់ដាត្រូវបានអនុម័តដោយ NAC នៅថ្ងៃទី11/04/03 តាមប្រកាសលេខ...ថ្ងៃ...ទី09/03។ NAC មានសមាជិក13នាក់។

4.4 Cambodia International Financial Reporting Standard (CIFRS) ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ ប្រើប្រាស់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១២។

4.5-KICPAA: (Kampuchea Institute Certified Public Accountant & Auditors) បានបង្កើតឡើងនៅថ្ងៃ19/03ដោយអនុក្រឹត្យ[2]។

### ២.២.៣ ទ្រឹស្តីពាក់ព័ន្ធស្តង់ដាគណនេយ្យអន្តរជាតិ

ស្តង់ដារបាយការណ៍ទាក់ទិននឹងហិរញ្ញវត្ថុអន្តរជាតិមាន៤គឺ

[2] សាកលវិទ្យាល័យវ៉ាន់ដា. (២០១៩). *Financial Reporting & Accounting Standard*. បោះពុម្ពលើកទី១១. ភាគ៣ ទំព័រទី៤-៥

1. IASs (International Accounting Standards)
2. IFRSs (International Financial Reporting Standards)
3. SICs (Standing Interpretations Committee Interpretations)
4. IFRICs (International Financial Reporting Interpretations Committee)[3]។

## ២.៣ ផលប្រយោជន៍នៃការប្រើប្រាស់ស្តង់ដាគណនេយ្យ

### ២.៣.១ ស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា

**ស្តង់ដា** គឺជាឯកសារដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងគ្នា និងបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ចដែលមានលក្ខណៈជាក្បួន ជាគោលការណ៍ណែនាំ ឬជាចរិតលក្ខណៈសម្រាប់សកម្មភាព ឬលទ្ធផលដើម្បីទុកសម្រាប់ប្រើប្រាស់ជារួមនិងជាបន្តបន្ទាប់ សំដៅជានាសម្រេចឱ្យបានដល់ចំណុចប្រសើរបំផុតនៃបរិបទមួយ។

**ស្តង់ដា** គឺជាឯកសារដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងគ្នា និងបានទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច ហើយឯកសារនោះផ្តល់នូវក្បួន គោលការណ៍ណែនាំ ឬចរិតលក្ខណៈសម្រាប់សកម្មភាព ឬលទ្ធផលរបស់វាទុកសម្រាប់ប្រើប្រាស់ជារួមនិងប្រើប្រាស់ឡើងវិញ ដើម្បីជានាឱ្យបានដល់ចំណុចប្រសើរបំផុតនៃបរិបទមួយ[4]។

**គណនេយ្យ** គឺសំដៅដល់ការកត់ត្រា ការចាត់ថ្នាក់ ការវាស់វែង ការផ្តុំបញ្ចូលគ្នា និងការបង្ហាញព័ត៌មានហិរញ្ញវត្ថុ[5]។

**គណនេយ្យ** គឺជាដំណើរនៃការកំណត់អត្តសញ្ញាណកម្ម ការវាស់វែង ការកត់ត្រា ការពិពណ៌នានិងការបកស្រាយនូវប្រតិបត្តិការសេដ្ឋកិច្ចរបស់អង្គភាព អាជីវកម្មមួយ នៅក្នុងកំឡុងពេលវេលាមួយដ៏ជាក់លាក់។ រាល់ព័ត៌មានគណនេយ្យទាំងអស់(ប្រតិបត្តិការ) ត្រូវពិពណ៌នាអំពីសាច់ប្រាក់[6]។

ស្តង់**ដាគណនេយ្យ** គឺជាសំណុំនៃគោលការណ៍ គោលការណ៍ស្តង់ដានិងនីតិវិធីទូទៅដែលកំណត់មូលដ្ឋាននៃគោលនយោបាយគណនេយ្យហិរញ្ញវត្ថុនិងការអនុវត្តន៍ក្នុងការរៀបចំនិងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។

ស្តង់ដាគណនេយ្យ គឺជាសំណុំទូទៅនៃគោលការណ៍ វិធាន និងនីតិវិធីដែលកំណត់អំពីមូលដ្ឋានរួមសម្រាប់គោលនយោបាយគណនេយ្យ ហិរញ្ញវត្ថុ និងការអនុវត្ត។ គោលបំណងចម្បងនៃស្តង់ដាគណនេយ្យគឺធានា នូវតម្លាភាព ភាពជឿទុកចិត្ត សង្គតិភាព និងភាពអាចប្រៀបធៀបបាននៃ របាយការណ៍ហិរញ្ញវត្ថុ[7]។

### ២.៣.២ ទ្រឹស្តីនៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧

ទ្រឹស្តីលំហូរសាច់ប្រាក់របស់ Robert Kiyosaki លោក Robert Kiyosaki បានបែងចែកវិធីមនុស្សបង្កើតចំណូលជា ៤ មូលដ្ឋានដែលក្នុងនោះមាន និយោជិក អ្នកធ្វើការឱ្យខ្លួនឯងអ្នកជំនួញនិងវិនិយោគិន។

[3] Deloitte. *IAS Plus*. Retrieved February, 17 2025, from https://www.iasplus.com/en/standards/ias
[4] Videoslearning. (August 5, 2023). *ស្តង់ដារ*. Retrieved February, 17 2025, from https://videoslearning.com/1-2887/
[5] KICPAA. (2023, December 06). *គណនេយ្យ*. Retrieved February, 17 2025, from https://shorturl.at/C0aLl
[6] KHsearch. (2019, March 26): *គណនេយ្យ*. Retrieved February, 20 2025, from https://www.khsearch.com/qna/17820
[7] វិទ្យាស្ថាន វ៉ាន់ដា. (២០១៩). *Intermediate Accounting*. បោះពុម្ពលើកទី១១. ភាគ៣ ទំព័រទី២

- **EMPLOYEE** | និយោជិក ប្រាក់ចំណូលបានមកពីប្រាក់ខែ ដែលជាចំណូលដែលមិនអាចគ្រប់គ្រងបាន។ មិនថាអ្នកខំប្រឹងធ្វើការយ៉ាងណាក៏ដោយ ប្រាក់ចំណូលនឹងត្រូវបានកំណត់ជានិច្ចរួចជាស្រេចដោយ និយោជក។
- **SELF-EMPLOYED** | អ្នកធ្វើការឱ្យខ្លួនឯង ចំណូលគឺពឹងផ្អែកទាំងស្រុងទៅលើពេលវេលាគាត់ក្នុងការធ្វើការ។ប្រសិនបើគាត់ឈប់ធ្វើការនោះប្រាក់ចំណូលរបស់គាត់ក៏ត្រូវបញ្ឈប់ដែរ។
- **BUSINESS OWNER** | អ្នកជំនួញ ចំណូលគឺពឹងបានមកពីការប្រើប្រាស់មនុស្ស ឱ្យធ្វើការទៅតាម System ដែលគេមាន
- **INVESTOR** | វិនិយោគិន វិនិយោគិនប្រើប្រាក់លុយដើម្បីបង្កើតលុយ។ ពួកគេមិនចាំបាច់ធ្វើការទេ ព្រោះលុយរបស់ពួកគេជាអ្នកធ្វើការឱ្យពួកគេ[8]។

[8] BIO Accelerator Program. Robert Kiyosak. (2020, July 28). *ទ្រឹស្តីលំហូរសាច់ប្រាក់របស់*. Retrieved February, 20 2025, from https://www.facebook.com/100064424693188/posts/2705208189799843/?rdid=Y7vPaSmEs91AiY2A&_rdc=2&_rdr

# ជំពូកទី៣
# សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា ៧

## ៣.១ ស្ថានភាពទូទៅនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា៧

### ៣.១.១ ប្រវត្តិរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា៧

ប្រវត្តិរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា របាយការណ៍តុល្យភាព (Balance Sheet) និងរបាយការណ៍ប្រាក់ចំណូល (Income Statement) ត្រូវបានទាមទារឱ្យមានក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រយៈពេលជាច្រើនឆ្នាំមកហើយ។ ប៉ុន្តែរបាយការណ៍លំហូរសាច់ប្រាក់ (Cash Flow Statement) ទើបតែត្រូវបានទាមទារដោយផ្លូវការនៅសហរដ្ឋអាមេរិក ចាប់ពីឆ្នាំ 1988 ទៅមកនេះ។ ទោះបីជាយ៉ាងណាក៏ដោយ របាយការណ៍លំហូរសាច់ប្រាក់នៅក្នុងរូបរាងណាមួយក៏ដោយក៏មានប្រវត្តិយូរមកហើយនៅសហរដ្ឋអាមេរិក។

នៅឆ្នាំ 1863, ក្រុមហ៊ុន Northern Central Railroad បានចេញផ្សាយសេចក្តីសង្ខេបអំពីប្រតិបត្តិការហិរញ្ញវត្ថុរបស់ខ្លួន ដែលមានការលើកឡើងអំពី ការទទួលសាច់ប្រាក់ និង ការចំណាយសាច់ប្រាក់ ក្នុងរយៈពេលមួយឆ្នាំ។ដោយសារថា ទ្រព្យសម្បត្តិឥណពន្ធ (Current Assets) អាចត្រូវបានពិចារណាថា ជាទ្រព្យសម្បត្តិដែលនៅជិតនឹងក្លាយជាសាច់ប្រាក់ និង បំណុលឥណពន្ធ (Current Liabilities) ក៏អាចត្រូវបានគេចាត់ទុកថាជាបំណុលដែលជិតត្រូវបង់ជាសាច់ប្រាក់ដែរ ដូច្នេះ ជម្រើសមួយផ្សេងទៀតនៃការផ្តោតលើលំហូរសាច់ប្រាក់គឺការពិនិត្យពីការប្រែប្រួលសុទ្ធនៃធនជានការងារ (Net Change in Working Capital) (គឺទ្រព្យសម្បត្តិឥណពន្ធ ដកបំណុលឥណពន្ធ)។ ក្នុងអារម្មណ៍មួយ working capital គឺស្មើនឹងសាច់ប្រាក់ បូកនឹងសាច់ប្រាក់សក្តានុពលក្នុងរយៈពេលខ្លី។

នៅឆ្នាំ 1902, ក្រុមហ៊ុន United States Steel Corporation បានចេញផ្សាយរបាយការណ៍ដែលរាយការណ៍អំពី មូលហេតុសំខាន់ៗនៃការប្រែប្រួលក្នុង "Funds" ក្នុងរយៈពេលមួយឆ្នាំ ដោយពន្យល់ថា Funds គឺស្មើនឹង ទ្រព្យសម្បត្តិឥណពន្ធដក Accounts Payable។ របាយការណ៍ Working Capital Funds Statement បានក្លាយជារឿងពេញនិយមកាន់តែខ្លាំងបន្ទាប់ពីឆ្នាំ 1920។

នៅឆ្នាំ 1971, APB (Accounting Principles Board) បានចេញផ្សាយ Opinion No. 19 ដែលកំណត់អោយ Funds Statement ត្រូវបានរួមបញ្ចូលជាមួយ បីរបាយការណ៍សំខាន់ ក្នុងរបាយការណ៍ប្រចាំឆ្នាំដល់អ្នកមានភាគហ៊ុន និងត្រូវបានគ្របដណ្តប់ក្នុងរបាយការណ៍ត្រួតពិនិត្យ (Auditor’s Report)។ Opinion No. 19 មិនបានកំណត់និយមន័យជាក់លាក់ ឬទ្រង់ទ្រាយតែមួយសម្រាប់ “funds” ទេ។ វាត្រូវបានហៅថា Statement of Changes in Financial Position។ ក្នុងទស្សវត្សរ៍ 1970, របាយការណ៍នេះមិនទទួលបានការយកចិត្តទុកដាក់ច្រើនទេហើយវាក៏មិនត្រូវបានពិភាក្សាក្នុងមុខវិជ្ជាគណនេយ្យដំបូងៗផងដែរ។

នៅដើមទស្សវត្សរ៍ 1980, Financial Executives Institute (FEI) បានលើកទឹកចិត្តឱ្យសមាជិករបស់ខ្លួន ប្រើ Cash Focus ក្នុងរបាយការណ៍នៃការផ្លាស់ប្តូរផ្នែកហិរញ្ញវត្ថុ។ នៅឆ្នាំ 1980, មានតែ 10% នៃក្រុមហ៊ុន Fortune 500 ប៉ុណ្ណោះ ដែលប្រើ Cash Focus ខណៈពេលដែល 90% ធ្វើរបាយការណ៍ផ្អែកលើ Net Changes in Working Capital។ ត្រឹមឆ្នាំ 1985, 70% នៃក្រុមហ៊ុនទាំងនេះ បានប្រើ Cash Focus។

ក្នុងកំឡុងពេលដូចគ្នានេះ FASB បានចេញផ្សាយ Statement of Financial Accounting Concepts No. 5 ដែលបានណែនាំថា ជាគំនិត គួរតែមាន Cash Flow Statement ជាផ្នែកមួយនៃ Full Set of Financial Statements។

នៅចុងឆ្នាំ 1987, FASB បានចេញផ្សាយ Statement No. 95 ដែលលុបចោល APB Opinion No. 19។ ជំនួសឱ្យការអនុញ្ញាតអោយមាននិយមន័យជាច្រើននៃ Funds ( ដូចជា Cash ឬ Working Capital ) និងទ្រង់ទ្រាយផ្សេងៗគ្នា FASB បានចេញសេចក្តីណែនាំឱ្យមាន Statement of Cash Flows ជាផ្នែកជំនួសឱ្យ Statement of Changes in Financial Position។ដោយសារតែ Cash Flow Statement គឺជារបាយការណ៍ដែលទើបមានប្រវត្តិថ្មី (ដោយយល់ថា គណនេយ្យពីរចុច មានប្រវត្តិរយៈពេល 500 ឆ្នាំ ហើយ) វាមិនទទួលបានការយកចិត្តទុកដាក់គ្រប់គ្រាន់នៅក្នុងការបង្រៀន និងការវិភាគ។ សៀវភៅគណនេយ្យជាច្រើន នៅតែទុកការសិក្សាអំពី Cash Flow Statement នៅចុងសៀវភៅ។បន្ថែមពីនេះ វិធីសាស្ត្របរិច្ឆេទនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុចាស់ៗ មិនបានបញ្ចូលការប្រើប្រាស់ទិន្នន័យពី Cash Flow Statement ទេ។ ដោយសារតែគំរូវិភាគបុរាណ ត្រូវបានអភិវឌ្ឍនៅអំឡុងពេលដែលទិន្នន័យ Cash Flow មិនទាន់មាន តុល្យការវិភាគគណនេយ្យសព្វថ្ងៃក៏នៅតែអាចប្រើបញ្ចូលគ្នាបាន។

ឧទាហរណ៍៖ ឧស្សាហកម្មជាច្រើននៅតែប្រើ EBITDA (Earnings Before Interest, Taxes, Depreciation, and Amortization) ដើម្បីវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ។ នៅពេលសួរថាហេតុអ្វីបានជាប្រើ EBITDA ពួកគេនឹងឆ្លើយថា “EBITDA approximates operating cash flow.”។ ប៉ុន្តែតើហេតុអ្វីបានជា Analyst មិនប្រើចំនួនសាច់ប្រាក់ពិតៗ? នេះគឺដោយសារទិន្នន័យពី Cash Flow Statement មិនទាន់ជាផ្នែកជាប់លាប់នៃប្រពៃណីវិភាគហិរញ្ញវត្ថុ។ ប៉ុន្តែការចូលរួមរបស់វានឹងកើនឡើងនៅពេលអនាគត។

## ៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

### ក.ចក្ខុវិស័យ

ចក្ខុវិស័យនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា (Cambodian International Financial Reporting Standards - CIFRS) គឺផ្តោតលើការអភិវឌ្ឍប្រព័ន្ធគណនេយ្យដែលមានភាពស្តង់ដា ស្របតាមអន្តរជាតិ និងជួយអាជីវកម្មកម្ពុជា មានភាពប្រសើរឡើងក្នុងការរាយការណ៍ហិរញ្ញវត្ថុ។

ចក្ខុវិស័យស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាសំខាន់ៗមានដូចជា៖

១. ការលើកកម្ពស់ភាពត្រឹមត្រូវ និងតម្លាភាព

- អភិវឌ្ឍប្រព័ន្ធគណនេយ្យដែលអាចធានាបាននូវភាពត្រឹមត្រូវនៃការរាយការណ៍ហិរញ្ញវត្ថុ។
- ផ្តល់សេចក្តីជំនួយដល់អាជីវកម្មក្នុងការប្រើស្តង់ដាដែលអាចជឿទុកចិត្តបាន។

២. ការផ្គូផ្គងជាមួយស្តង់ដាអន្តរជាតិ

- កម្ពុជាមានបំណងអនុវត្ត CIFRS ដែលផ្អែកលើ IFRS ដើម្បីធ្វើប្រព័ន្ធគណនេយ្យស្របទៅនឹងបទដ្ឋានអន្តរជាតិ។
- ការជំរុញស្ថាប័នធុរកិច្ចអនុវត្ត CIFRS ឬ CIFRS for SMEs។

៣. ការបង្កើតភាពទាក់ទាញសម្រាប់វិនិយោគិនអន្តរជាតិ

- ដោយមានស្តង់ដាគណនេយ្យដែលជឿទុកចិត្ត អាជីវកម្មកម្ពុជានឹងអាចទាក់ទាញវិនិយោគិនអន្តរជាតិ។

- ជួយអាជីវកម្មក្នុងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុដោយផ្អែកលើទិន្នន័យគណនេយ្យដែលមានគុណភាព។

៤. ការរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

- ផ្តល់ជំនួយដល់ក្រុមហ៊ុនក្នុងការរៀបចំការរាយការណ៍ហិរញ្ញវត្ថុដែលអាចបំពេញតាមតម្រូវការសេដ្ឋកិច្ចកម្ពុជា។
- លើកកម្ពស់ការចូលរួមរបស់កម្ពុជាក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ។

៥. ការអប់រំ និងបណ្តុះបណ្តាល

- ផ្តល់ការបណ្តុះបណ្តាលដល់អ្នកជំនាញគណនេយ្យ អ្នកវាយតម្លៃ និងអ្នកសវនកម្ម។
- បង្កើតប្រព័ន្ធអប់រំ និងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹង CIFRS ដើម្បីជំរុញការអនុវត្តកាន់តែមានប្រសិទ្ធភាព។

ចក្ខុវិស័យនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា គឺការចាប់អារម្មណ៍លើភាពត្រឹមត្រូវស្របតាមស្តង់ដាអន្តរជាតិ និងបង្កើតបរិស្ថានសេដ្ឋកិច្ចដែលអាចទាក់ទាញវិនិយោគិន។ NAC និង MEF កំពុងបន្តការអភិវឌ្ឍន៍ប្រព័ន្ធនេះ ដើម្បីធានាថាកម្ពុជាមានប្រព័ន្ធគណនេយ្យប្រកបដោយវិជ្ជាជីវៈ និងទំនុកចិត្ត។

**ខ.បេសកកម្ម**

បេសកកម្មនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា (Cambodian International Financial Reporting Standards - CIFRS) គឺបង្កើតប្រព័ន្ធគណនេយ្យដែលមានភាពស្មើភាពនិងប្រសិទ្ធភាពដើម្បីធានាការរាយការណ៍ហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងស្របតាមស្តង់ដាអន្តរជាតិ។

បេសកកម្មនៃស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជាសំខាន់ៗមានដូចជា៖

១. ធានាប្រកបដោយតម្លាភាព និងជឿទុកចិត្ត

- រៀបចំស្តង់ដាក្នុងវិស័យគណនេយ្យ ដើម្បីធានាថាការរាយការណ៍ហិរញ្ញវត្ថុមានភាពត្រឹមត្រូវ។
- បង្កើតប្រព័ន្ធគណនេយ្យដែលអាចជឿទុកចិត្តបាន សម្រាប់ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ។

២. ផ្គូផ្គងជាមួយស្តង់ដាអន្តរជាតិ

- អភិវឌ្ឍន៍ និងអនុវត្ត CIFRS ដើម្បីធានាថាប្រព័ន្ធគណនេយ្យនៅកម្ពុជាមានលក្ខណៈស៊ុំទៅនឹង IFRS។
- លើកកម្ពស់ការអនុវត្ត CIFRS for SMEs សម្រាប់សហគ្រាសទំហំតូច និងមធ្យម។

៣. បង្កើតបរិស្ថានល្អសម្រាប់វិនិយោគិន

- ផ្តល់ព័ត៌មានហិរញ្ញវត្ថុដែលមានគុណភាពដល់វិនិយោគិន និងអ្នកប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុ។
- ជួយអាជីវកម្មទាក់ទាញវិនិយោគិនអន្តរជាតិ និងជួយក្នុងការពង្រឹងទីផ្សារហិរញ្ញវត្ថុកម្ពុជា។

៤. ការអប់រំ និងការលើកកម្ពស់វិជ្ជាជីវៈ

- បណ្តុះបណ្តាលអ្នកគណនេយ្យ និងសវនកម្មដើម្បីធានាថាពួកគេអាចអនុវត្តតាមស្តង់ដាត្រឹមត្រូវ។
- រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាអំពី CIFRS ដើម្បីជួយអាជីវកម្មក្នុងការយល់ដឹង និងអនុវត្តស្តង់ដាឱ្យបានល្អ។

៥. ការចូលរួមក្នុងអភិវឌ្ឍសេដ្ឋកិច្ច

- លើកកម្ពស់ប្រព័ន្ធគណនេយ្យដែលអាចចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

- ផ្តល់ជំនួយដល់ក្រុមហ៊ុនក្នុងការរៀបចំការរាយការណ៍ហិរញ្ញវត្ថុដែលអាចបំពេញតាមតម្រូវការរដ្ឋាភិបាលនិងស្ថាប័នហិរញ្ញវត្ថុ។

បេសកកម្មនៃ CIFRS នៅកម្ពុជាគឺ បង្កើតប្រព័ន្ធគណនេយ្យប្រកបដោយតម្លាភាព ស្របតាមស្តង់ដាអន្តរជាតិ និងជួយអាជីវកម្មទាក់ទាញវិនិយោគិន។ NAC និង MEF កំពុងធ្វើការលើការអភិវឌ្ឍន៍ និងអនុវត្តស្តង់ដាដើម្បីធានាថាការរាយការណ៍ហិរញ្ញវត្ថុមានភាពទុកចិត្តបាន។

**គ.គោលដៅ** :ផ្តល់ព័ត៌មានអំពីចំណូលនិងចំណាយសាច់ប្រាក់របស់អង្គភាពជាទម្រង់របាយការណ៍លំហូរសាច់ប្រាក់ ដើម្បីឲ្យអ្នកប្រើប្រាស់អាចវាយតម្លៃស្ថានភាពសាច់ប្រាក់ និងសមត្ថភាពក្នុងការបង្កើតនិងប្រើប្រាស់សាច់ប្រាក់។

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

ក. រចនាសម្ព័ន្ធគ្រប់គ្រង




### រចនាសម្ព័ន្ធនៃការគ្រប់គ្រង

- ឯកឧត្តម **ប៊ូ ថារិន** អគ្គនាយក
- លោក **ជា ចាន់ថា** អគ្គនាយករង

- លោក **ជេន ផាត** អគ្គនាយករង
- លោកស្រី **នាន បូនី** អគ្គនាយករង

## ៣.២ គោលបំណងរបស់ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

### ៣.២.១ ការប្រើប្រាស់របាយការណ៍លំហូរសាច់ប្រាក់

របាយការណ៍លំហូរសាច់ប្រាក់ធ្វើសមាហរណកម្មព័ត៌មាននៅលើតារាងតុល្យការណ៍ និងរបាយការណ៍លទ្ធផល។ វាបង្ហាញផលប៉ះពាល់លើលំហូរសាច់ប្រាក់សុទ្ធរបស់ក្រុមហ៊ុន និងបម្រែបម្រួលសមាសជាតុផ្សេងៗ នៅក្នុងតារាងតុល្យការ។ របាយការណ៍សាច់ប្រាក់គឺជារបាយការណ៍មួយបង្ហាញអំពីលំហូរសាច់ប្រាក់ចូល និងលំហូរសាច់ប្រាក់ចេញ ដែលកើតឡើងពាក់ព័ន្ធទៅនឹងសកម្មភាពរបស់អង្គភាពអាជីវកម្មនៅក្នុងអំឡុងពេលមួយ។ របាយការណ៍ហូរសាច់ប្រាក់ អាចផ្តល់លទ្ធភាពដល់អ្នកប្រើប្រាស់ទាំងឡាយ វាយតម្លៃលើបម្រែបម្រួលនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាពរចនាសម្ព័ន្ធហិរញ្ញវត្ថុ(សន្ទនីយភាព និងសោធនភាព)។ ព័ត៌មានលំហូរសាច់ប្រាក់នេះ មានសារៈប្រយោជន៍ក្នុងការវាយតម្លៃលទ្ធភាពរបស់អង្គភាពក្នុងការបង្កើតសាច់ប្រាក់និងសាច់ប្រាក់ប្រហាក់ប្រហែល។ របាយការណ៍លំហូរសាច់ប្រាក់ ត្រូវបានចាត់ថ្នាក់តាមសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន។

•សកម្មភាពប្រតិបត្តិការ ទឹកប្រាក់នៃលំហូរសាច់ប្រាក់ដែលកើតមកពីសកម្មភាពប្រតិបត្តិការគឺជាការចង្អុលបង្ហាញដ៏សំខាន់អំពីវិសាលភាពប្រតិបត្តិការរបស់អង្គភាពដែលបានបង្កើតលំហូរសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់សងបំណុលសម្រាប់រក្សាលទ្ធភាពប្រតិបត្តិការរបស់អង្គភាពសម្រាប់ទូទាត់ភាគលាភនិងសម្រាប់ការវិនិយោគទុនថ្មីដោយពុំចាំបាច់ពឹងផ្អែកលើហិរញ្ញប្បទានពីប្រភពខាងក្រៅ ។ ព័ត៌មានស្តីពីសមាសភាគជាក់លាក់នៃប្រវត្តិលំហូរសាច់ប្រាក់ប្រតិបត្តិការរួមជាមួយនឹងព័ត៌មានដទៃទៀតមានសារៈប្រយោជន៍ក្នុងការព្យាករណ៍លំហូរសាច់ប្រាក់ពីប្រតិបត្តិការនាពេលអនាគត។ លំហូរសាច់ប្រាក់របស់សកម្មភាពប្រតិបត្តិការគឺសំខាន់បំផុតបានមកពី សកម្មភាពបង្កើតចំណូលចំបង របស់អង្គភាព ។ ដូច្នេះហើយលំហូរសាច់ ប្រាក់ទាំងនោះជាទូទៅគឺជាលទ្ធផលពីប្រតិបត្តិការនិងព្រឹត្តិការណ៍ដែលបានកត់ត្រាដើម្បីកំណត់ប្រាក់ចំណេញឬខាត។ ខាងក្រោមនេះជាឧទាហរណ៍នៃលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពប្រតិបត្តិការ÷

(ក)សាច់ប្រាក់ដែលទទួលបានពីការលក់ទំនិញនិងការផ្តល់សេវាកម្ម។

(ខ)សាច់ប្រាក់ដែលទទួលបានពីសួយសារ ថ្លៃឈ្នួល កម្រៃជើងសារ និងចំណូលផ្សេងៗ ។

(គ)សាច់ប្រាក់ចំណាយ ឱ្យអ្នកផ្គត់ផ្គង់ និងសេវាកម្ម ។

(ឃ)សាច់ប្រាក់ចំណាយឱ្យនិយោជិក និងប្រាក់ចំណាយជំនួសនិយោជិក ។

(ង)សាច់ប្រាក់ចំណូល និងសាច់ប្រាក់ចំណាយរបស់ អង្គភាពធានា រ៉ាប់រង ចំពោះបុព្វលាភ និងការទាមទារ ធនលាភ និងផលប្រ យោជន៍គោលនយោបាយផ្សេងៗទៀត។

(ច)សាច់ប្រាក់ចំណាយនិងសាច់ប្រាក់បង្វិលសងត្រឡប់មកវិញនៃពន្ធលើប្រាក់ចំណេញលុះត្រាតែសាច់ប្រាក់នោះមិនអាចកំណត់បានច្បាស់លាស់ថាជា សកម្មភាពហិរញ្ញប្បទាន និងសកម្មភាពវិនិយោគ។

(ឆ)សាច់ប្រាក់ទទួលបាននិងសាច់ប្រាក់ចំណាយពីកិច្ចសន្យាដែលទុកសម្រាប់គោលបំណងដោះដូរឬពាណិជ្ជកម្ម។

ប្រតិបត្តិការខ្លះ ដូចជាការលក់ធាតុមួយនៃរោងចក្រអាចនាំឱ្យមានការ ចំណេញឬខាតដែលត្រូវបានដាក់បញ្ចូលទៅក្នុងប្រាក់ចំណេញ ឬខាតដែលបានទទួលស្គាល់។ លំហូរសាច់ប្រាក់ទាក់ទងនឹងប្រតិបត្តិការនេះ គឺជាលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពវិនិយោគ។ ទោះជាយ៉ាងណាក៏ដោយ ប្រាក់ចំណាយដើម្បីផលិត ឬទិញទ្រព្យសកម្មដើម្បីទុកជួលឱ្យអ្នកដទៃ និងបន្តមកទៀតរក្សាទុកសម្រាប់លក់ ដូចដែលបានពណ៌នានៅក្នុងកថាខណ្ឌ៦៨ក នៃ ស.គ.អ ១៦ ទ្រព្យសម្បត្តិរោងចក្រនិងឧបករណ៍ គឺជាលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពប្រតិបត្តិការ។ សាច់ប្រាក់ទទួលបានដែលបានមកពីការការជួលនិងការលក់នៃទ្រព្យសម្បត្តិទាំងនោះនាពេលបន្ទាប់ គឺជាលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពប្រតិបត្តិការ។ អង្គភាពមួយអាចរក្សាទុកមូលប័ត្រ និងកម្ចីដើម្បីធ្វើការដោះដូរ ឬការធ្វើពាណិជ្ជកម្មដែលក្នុងករណីនេះ វាមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងសន្និធិដែលត្រូវបានទិញជាពិសេសដើម្បីលក់បន្ត។ អាស្រ័យហេតុនេះលំហូរសាច់ប្រាក់ពីការទិញនិងការលក់មូលប័ត្រសម្រាប់ជួញដូរត្រូវចាត់ថ្នាក់ជាសកម្មភាពប្រតិបត្តិការ។ ស្រដៀងគ្នានេះដែរសាច់ប្រាក់បុរេប្រទាននិងកម្ចីដែលផ្តល់ដោយស្ថាប័នហិរញ្ញវត្ថុជាធម្មតាត្រូវបានគេចាត់ថ្នាក់ជាសកម្មភាពប្រតិបត្តិការនៅពេលដែលសាច់ប្រាក់ទាំងនោះទាក់ទងនឹងសកម្មភាពបង្កើតចំណូលសំខាន់របស់អង្គភាពនោះ។

•សកម្មភាពវិនិយោគ ការលាតត្រដាងដាច់ដោយឡែកពីគ្នា នៃលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពវិនិយោគមានសារៈសំខាន់ ពីព្រោះលំហូរសាច់ប្រាក់តំណាងឱ្យវិសាលភាពនៃខ្ទង់ចំណាយណាមួយដែលត្រូវធ្វើឡើងសម្រាប់ជាធនធានដើម្បីបង្កើតចំណូល និងលំហូរសាច់ប្រាក់នាពេលអនាគត។ មានតែការចំណាយដែលនាំឱ្យទ្រព្យសកម្មត្រូវបានគេទទួលស្គាល់ក្នុងរបាយការណ៍ស្ថានការណ៍ហិរញ្ញវត្ថុទេទើបសមស្របសម្រាប់ការចាត់ថ្នាក់ជាសកម្មភាពវិនិយោគ។ ខាងក្រោមនេះជាឧទាហរណ៍នៃលំហូរសាច់ប្រាក់បានមកពីសកម្មភាពវិនិយោគ÷

(ក)សាច់ប្រាក់ចំណាយសម្រាប់ទិញទ្រព្យរោងចក្រនិងឧបករណ៍ទ្រព្យសកម្មអរូបីនិងទ្រព្យសកម្មរយៈពេលវែងផ្សេងៗទៀត។ ការចំណាយទាំងនេះរួមមានការចំណាយដែលទាក់ទងនឹងថ្លៃដើមការអភិវឌ្ឍន៍ដែលបានធ្វើមូលធនកម្មនិងទ្រព្យរោងចក្រនិងឧបករណ៍ដែលត្រូវបានសាងសង់ដោយអង្គភាពខ្លួនឯង។

(ខ)សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យរោងចក្រនិងឧបករណ៍ទ្រព្យសកម្មអរូបីនិងទ្រព្យសកម្មរយៈពេលវែងផ្សេងៗទៀត។

(គ)ការចំណាយសាច់ប្រាក់ដើម្បីទិញឧបករណ៍បំណុលឬមូលធនផ្ទាល់នៃអង្គភាពផ្សេងទៀតនិងភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន (ក្រៅពីការចំណាយសម្រាប់ឧបករណ៍ទាំងឡាយដែលចាត់ទុកជាសាច់ប្រាក់ប្រហាក់ប្រហែលឬដែលរក្សាទុកសម្រាប់គោលបំណង ជួញដូរ) ។

(ឃ) សាច់ប្រាក់ទទួលបានពីការលក់ឧបករណ៍បំណុល ឬមូលធននៃអង្គភាពផ្សេងទៀត និងអត្ថប្រយោជន៍នៅក្នុងអង្គភាពដាក់ហ៊ុនរួមគ្នា(ក្រៅពីការចំណាយសម្រាប់ឧបករណ៍ទាំងឡាយ ដែលចាត់ទុកជាសមមូលសាច់ប្រាក់ឬដែលកាន់ទុកសម្រាប់គោលបំណង ជួញដូរ) ។

(ង)សាច់ប្រាក់បុរេប្រទាននិងកម្ចីឱ្យទៅភាគីដទៃ(ក្រៅពីបុរេប្រទាននិងកម្ចីដែលត្រូវបានធ្វើឡើងដោយស្ថាប័នហិរញ្ញវត្ថុមួយ)។

(ច)សាច់ប្រាក់ទទួលបានពីការទូទាត់បុរេប្រទាននិងកម្ចីឱ្យទៅភាគីដទៃ (ក្រៅពីបុរេប្រទាន និងកម្ចីដែលត្រូវបានធ្វើឡើងដោយស្ថាប័នហិរញ្ញវមួយ) ។

(ឆ)សាច់ប្រាក់ចំណាយសម្រាប់កិច្ចសន្យានាពេលអនាគតកិច្ចសន្យានាពេលខាងមុខកិច្ចសន្យាជម្រើសកិច្ចសន្យាប្តូរលើកលែងតែនៅពេលដែលកិច្ចសន្យាត្រូវបានរក្សាសម្រាប់ជួញដូរឬពាណិជ្ជកម្មឬការបង់ប្រាក់ទាំងឡាយណាដែលត្រូវបានគេចាត់ថ្នាក់ថាជាសកម្មភាពហិរញ្ញប្បទាន។

(ជ)សាច់ប្រាក់ចំណូលសម្រាប់កិច្ចសន្យានាពេលខាងមុខកិច្ចសន្យាជម្រើស កិច្ចសន្យាប្តូរលើកលែងនៅពេលដែលកិច្ចសន្យាត្រូវបានរក្សាទុកសម្រាប់ជួញដូរ ឬពាណិជ្ជកម្មឬការទទួលប្រាក់ទាំងឡាយណាដែលត្រូវបានគេចាត់ថ្នាក់ជាសកម្មភាពហិរញ្ញប្បទាន។ នៅពេលដែលកិច្ចសន្យាត្រូវបានកត់ត្រាថាជាការទប់ស្កាត់ហានិភ័យនៃស្ថានភាពមួយដែលបានកំណត់នោះលំហូរសាច់ប្រាក់នៃកិច្ចសន្យាត្រូវបានចាត់ថ្នាក់នៅក្នុងលក្ខណៈដូចគ្នាទៅនឹងលំហូរសាច់ប្រាក់នៃស្ថានភាពមួយដែលកំពុងត្រូវបានទប់ស្កាត់ហានិភ័យ ។

•សកម្មភាពហិរញ្ញប្បទាន ការលាតត្រដាងដាច់ដោយឡែកនៃលំហូរសាច់ប្រាក់ ដែលបានមកពីសកម្មភាពហិរញ្ញប្បទានមានសារៈសំខាន់ណាស់ពីព្រោះវាមានប្រយោជន៍សម្រាប់អ្នកផ្តល់មូលធនដល់អង្គភាពក្នុងការព្យាករណ៍លើការទាមទារដែលត្រូវទទួលបានពីលំហូរសាច់ប្រាក់នាពេលអនាគត។ខាងក្រោមនេះជាឧទាហរណ៍លំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពហិរញ្ញប្បទាន÷

(ក)សាច់ប្រាក់បានមកពីការបោះលក់ភាគហ៊ុនមូលធនផ្សេងៗទៀត

(ខ)សាច់ប្រាក់ចំណាយឱ្យម្ចាស់ភាគហ៊ុនទាំងឡាយដើម្បីទទួលបានឬទិញភាគហ៊ុនរបស់អង្គភាពត្រឡប់មកវិញ

(គ)សាច់ប្រាក់បានមកពីការបោះលក់លិខិតបំណុលបំណុលលិខិតសញ្ញាប័ណ្ណ ប័ណ្ណបញ្ចាំនិងការសុំខ្ចីរយៈពេលខ្លីឬវែងផ្សេងទៀតរបាយការណ៍សាច់ប្រាក់គឺជារបាយការណ៍មួយបង្ហាញអំពីលំហូរសាច់ប្រាក់ចូលនិងលំហូរសាច់ប្រាក់ចេញដែលកើតឡើងពាក់ព័ន្ធទៅនឹងសកម្មភាពរបស់អង្គភាពអាជីវកម្មនៅក្នុងអំឡុងពេលមួយ ។

(ឃ)ការសងបំណុលជាសាច់ប្រាក់

(ង)ការទូទាត់សាច់ប្រាក់ដោយអ្នកជួលសម្រាប់កាត់បន្ថយបំណុលដែលនៅជំពាក់ដែលពាក់ព័ន្ធទៅនឹង ភតិសន្យាហិរញ្ញវត្ថុ ។

**៣.២.២.ការរាយការណ៍អំពីលំហូរសាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគនិងហិរញ្ញប្បទាន**

អង្គភាពមួយ ត្រូវធ្វើការរាយការណ៍ពីលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពប្រតិបត្តិការក្នុងនោះប្រើះ

ក-ដោយប្រើវិធីសាស្ត្រផ្ទាល់ ដែលលំដាប់ចម្បងៗនៃសាច់ប្រាក់ចំណូលដុល និងសាច់ប្រាក់ចំណាយដុលត្រូវបានបង្ហាញ ។

ខ-វិធីសាស្ត្រប្រយោល ដែលចំណេញពិតឬខាតពិត ត្រូវបានយកមកធ្វើនិយ័តភាពសម្រាប់ផលប៉ះពាល់នៃប្រតិបត្តិការនៃប្រភេទមិនមែនជាសាច់ប្រាក់ (ការពន្យារ ឬបង្ករ នៃអតីតកាល ឬអនាគតនៃចំណូលសាច់ប្រាក់ និងចំណាយសាច់ប្រាក់ ដែលបានមកពីប្រតិបត្តិការ) និងធាតុនានានៃចំណូល ឬ ចំណាយ ដែលភ្ជាប់ជាមួយនឹងលំហូរសាច់ប្រាក់ពីការវិនិយោគ ឬហិរញ្ញប្បទាន។

អង្គភាពត្រូវបានលើកទឹកទឹកចិត្ត ដើម្បីរាយការណ៍ពីលំហូរសាច់ប្រាក់ចេញពីប្រតិបត្តិការដោយប្រើវិធីសាស្ត្រផ្ទាល់។ វិធីសាស្ត្រផ្ទាល់ផ្តល់ពត៌មានដែលមានប្រយោជន៍ក្នុងការប៉ាន់ស្មានពីលំហូរសាច់ប្រាក់នាពេល

អនាគត ហើយដែលមិនអាចអនុវត្តបានក្នុងវិធីសាស្ត្រប្រយោល។ តាមការ អនុវត្តវិធីសាស្ត្រផ្ទាល់ ពត៌មានស្តីពីលំដាប់ចម្បងនៃសាច់ប្រាក់ចំណូល និង ចំណាយដុលផងដែរបានមកពីៈ

ក. ចេញពីគណនេយ្យកម្មរបស់អង្គភាព

ខ. ដោយធ្វើនិយត័ភាព ការលក់ ថ្លៃដើមលក់ (ចំណូលការប្រាក់ និងចំណូលប្រហាក់ ប្រហែលនឹងការប្រាក់និងចំណាយការប្រាក់និងការចំណាយប្រហាក់ប្រហែលនឹងការប្រាក់ចំពោះស្ថាបន័ហិរញ្ញវត្ថុមួយ)និងធាតុដទៃទៀត ក្នុងរបាយការណ៍លទ្ធផលទៅលើៈ

១-បម្រែបម្រួលក្នុងកំឡុងពេលនៃការិយបរិច្ឆេទនៃសន្និធិ និងប្រតិបត្តិការនៃចំណូល និងចំណាយ។

២-ធាតុដែលមិនមានលក្ខណៈជាសាច់ប្រាក់ផ្សេងៗ

៣-ធាតុផ្សេងៗទៀត ដែលធាតុនោះមានផលប៉ះពាល់ដល់សាច់ប្រាក់នោះ គឺជាលំហូរសាច់ប្រាក់នៃការវិនិយោគ ឬហិរញ្ញប្បទាន។

នៅក្រោមវិធីសាស្ត្រមិនផ្ទាល់ សាច់ប្រាក់បានមកត្រូវបានកំណត់ ការធ្វើនិយ័តភាព ប្រាក់ចំណេញ ឬខាតចំពោះឥទ្ធិពលនេះ

ក. ការប្រែប្រួល កំឡុងការិយបរិច្ឆេទនៃសន្និធិគណនីត្រូវទទួល និងគណនីត្រូវបង់។

ខ.ធាតុមិនមែនសាច់ប្រាក់ ដូចជា រំលស់ សំវិធានធន ពន្ធពន្យា ចំណេញ ឬប្រាក់ចំណេញ មិនបែងចែកនៃក្រុមហ៊ុនមេសម្ព័ និងភាគកម្មអប្បភាគ។

គ.ធាតុទាំងអស់ផ្សេងទៀតដែលឥទ្ធិពលសាច់ប្រាក់របស់វាគឺលំហូរសាច់ប្រាក់វិនិយោគឬហិរញ្ញប្បទាន។

វិធីជំនួសមួយទៀត លំហូរសាច់ប្រាក់អាចដាក់បង្ហាញនៅក្រោម វិធីសាស្ត្រមិនផ្ទាល់តាមរយៈបង្ហាញចំណូល និងចំណាយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល និងការប្រែប្រួល កំឡុងការិយបរិច្ឆេទនៃសន្និធិ និងគណនីត្រូវទទួល និងគណនីត្រូវសង។

**៣.២.៣ ការរាយការណ៍អំពីលំហូរសាច់ប្រាក់តាមមូលដ្ឋានពិត**

លំហូរសាច់ប្រាក់ដែលកើតចេញពី សកម្មភាពប្រតិបត្តិការ វិនិយោគ និងហិរញ្ញប្បទាន អាចរាយការណ៍តាមវិធីមូលដ្ឋានពិតៈ

ក-សាច់ប្រាក់ចំណូល និងចំណាយក្នុងនាមអតិថិជន នៅពេលដែលលំហូរសាច់ប្រាក់ ឆ្លុះបញ្ចាំងពីសកម្មភាពរបស់អតិថិជន ហើយដែលសកម្មភាពទាំងនោះ មិនមែនជាសកម្មភាពរបស់អង្គភាពឡើយ។

ខ-សាច់ប្រាក់ចំណូល និងចំណាយចំពោះធាតុ ដែលអាចទទួលផលបានរហ័ស មានចំនួនធំ និង ក្នុងរយៈពេលខ្លី ។

ឧទាហរណ៍នៃសាច់ប្រាក់ចំណូល និងចំណាយ ដែលបានចែងនៅក្នុងកថាខ័ណ្ឌ២២ ចំណុច(ក) គឺ ៖

ក. ការទទួលស្គាល់ និងការទូទាត់វិញ នៃប្រាក់បញ្ញើរបស់ធនាគារ។

ខ. មូលនិធិដែលរក្សាទុកសម្រាប់អតិថិជន ដោយអង្គភាពវិនិយោគទុនមួយ។

គ. បានប្រមូលថ្លៃជួលជំនួសម្ចាស់ទ្រព្យ និងបង់ថ្លៃជួលទៅអោយម្ចាស់ទ្រព្យ ។

ឧទាហរណ៍ នៃសាច់ប្រាក់ចំណូលនិងចំណាយ ដែលចែងនៅក្នុងកថាខណ្ឌ ២២ ចំណុច(ខ) គឺជាការធ្វើបុរេប្រទាន និងការទូរទាត់ឡើងវិញនេះ

ក. ចំនួនប្រាក់ដើម ដែលពាក់ពន្ធ័ទៅនឹង បណ្ណឥណទានរបស់អតិថិជន

ខ. ការទិញនិងការលក់នៃការវិនិយោគ

គ. កម្ចីរយៈពេលខ្លីផ្សេងៗ ឧទាហរណ៍ កម្ចីទាំងឡាយណា ដែលមានរយៈពេលកំណត់តិចជាង ឬស្មើ៣ខែ

លំហូរសាច់ប្រាក់ទាំងឡាយណា ដែលបានមកពីសកម្មភាពនីមួយៗនៃស្ថាប័នហិរញ្ញវត្ថុ ដូចខាងក្រោម 200B ត្រូវធ្វើការរាយការណ៍ ដោយផ្អែកតាមមូលដ្ឋានចំណូលនិងចំណាយ ៖

ក- សាច់ប្រាក់ចំណូលនិងចំណាយសម្រាប់ការទទួលយកនិងការទូរទាត់ឡើងវិញនៃប្រាក់ដំកល់ក្នុងការិយបរិច្ឆេទកំណត់ថេរមួយ។ របស់ស្ថាប័នហិរញ្ញវត្ថុនានា។

ខ- ការដាក់ប្រាក់ដំកល់ និងការដកប្រាក់ដំកល់វិញរបស់ស្ថាប័នហិរញ្ញវត្ថុនានា។

គ-ប្រាក់បុរេប្រទាន និងប្រាក់កម្ចីរបស់អតិថិជន និងការទូរទាត់ឡើងវិញ ចំពោះប្រាក់បុរេប្រទាន និងប្រាក់កម្ចីទាំងនោះ ។

### ៣.២.៤ ធាតុពិសេស ការប្រាក់និងភាគលាភរបស់របាយការណ៍លំហូរសាច់ប្រាក់

**. ធាតុពិសេស**

លំហូរសាច់ប្រាក់រួមជាមួយធាតុពិសេសត្រូវបានចាត់ថ្នាក់ថាជាធាតុដែលបានមកពីសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ ឬសកម្មភាពហិរញ្ញប្បទានឱ្យស្របតាមប្រតិបត្តិការ ដែលវាបានកើតឡើង និងត្រូវបានកំណត់បង្ហាញដាច់ដោយឡែក។

Ex-1 យើងបើកប្រាក់ពីធនាគារចំនួន $50,000 សម្រាប់បើកប្រាក់ខែដល់បុគ្គលិក និងកម្មករតាមផ្លូវត្រូវចោរពួនស្ទាក់ប្លន់យកអស់ ។ នេះគឺ Extraordinary Items ដែលត្រូវបង្ហាញការខាតបង់នេះ ក្នុង IS និង Step Extraordinary Items។ ចុះចំណែក Cash flow វិញ។ ឆ្លើយ៖ Operating Activities ។

Ex-2 ឧបមាថាប្រាក់នោះយកមកទិញដីទុកវិញ។ តើ Classified ជាអ្វី? ឆ្លើយ៖ Investing Activities ។

Ex-3 យើងបោះ Security លក់ប្រមូលសាច់ប្រាក់ $ 1,000,000 ។ ប្រាក់នោះត្រូវភ្លើងឆេះអស់។ នេះគឺជា Extraordinary។ តើ Classified ក្នុង Clash flow ជាអ្វី? ឆ្លើយ៖ Financing Activities ។

**. ការប្រាក់ និងភាគលាភ**

លំហូរសាច់ប្រាក់ ដែលបានមកពីការប្រាក់និងភាគលាភ ចំណូលនិងចំណាយនៃធាតុនីមួយៗត្រូវបានធ្វើកំណត់បង្ហាញដាច់ដោយឡែកពីគ្នា។ធាតុនីមួយៗ ត្រូវតែចាត់ថ្នាក់នៅក្នុងលក្ខណៈមិនប្រែប្រួលពីគ្រាមួយទៅគ្រាមួយទៀតទាំងនៅក្នុងសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគឬក្នុងសកម្មភាពហិរញ្ញប្បទាន។

ចំនួនសរុបនៃការប្រាក់ ដែលត្រូវចំណាយក្នុងការិយបរិច្ឆេទមួយ ត្រូវបានកំណត់បង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ថា តើវាត្រូវបានទទួលស្គាល់ ជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល ឬ ក៏ត្រូវបានធ្វើមូលធនកម្ម ដែលជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យសកម្ម ដោយយោងតាមវិធីសាស្ត្រជម្រើសនៃ សគក ២៣ បន្ទុកប្រាក់កម្ចី។

ការប្រាក់ដែលត្រូវចំណាយ និងការប្រាក់និងភាគលាភដែលត្រូវទទួលជាធម្មតាត្រូវចាត់ថ្នាក់ជាលំហូរសាច់ប្រាក់ដែលបានពីសកម្មភាពប្រតិបត្តការរបស់ស្ថាបន័ហិរញ្ញវត្ថុមួយ។ ការប្រាក់ដែលត្រូវចំណាយនិងការ

ប្រាក់និងភាគលាភ ដែលត្រូវទទួលត្រូវចាត់ថ្នាក់ថាជាលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពប្រតិបត្តិការ សម្រាប់ប្រភេទផ្សេងៗរបស់អង្គភាពពីព្រោះ វាចូលរួមក្នុងការកំណត់នូវប្រាក់ចំណេញ និងខាតពិត។ ជម្រើសមួយទៀត ការប្រាក់ចំណាយ និងការប្រាក់ និងភាគលាភទទួលបានអាចចំណាត់ថ្នាក់ជាលំហូរសាច់ប្រាក់ហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់វិនិយោគរៀងគ្នា ពីព្រោះវាទាំងនេះ គឺជាថ្លៃដើមនៃការទទួលបានធនធានហិរញ្ញវត្ថុ ឬទិន្នផលទទួលបានលើការវិនិយោគ។

ភាគលាភដែលបានចំណាយត្រូវចាត់ថ្នាក់ថា ជាលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពហិរញ្ញប្បទាន ពីព្រោះវាជាថ្លៃដើមដែលបានមកពីធនធានហិរញ្ញវត្ថុ។ ជម្រើសមួយទៀតភាគលាភដែលចែកចាយអាចចំណាត់ថ្នាក់ ជាបំណែកមួយនៃលំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ ដើម្បីជួយអ្នកប្រើប្រាស់ដើម្បីកំណត់ អំពីលទ្ធភាពរបស់អង្គភាពក្នុងការបែងចែកភាគលាភចេញពីលំហូរ សាច់ប្រាក់ប្រតិបត្តិការ។

**.ពន្ធលើប្រាក់ចំណេញ**

លំហូរសាច់ប្រាក់ដែលកើតឡើងពីពន្ធលើប្រាក់ចំណេញ ត្រូវកំណត់បង្ហាញដាច់ដោយឡែក និងត្រូវបានចាត់ថ្នាក់ថា ជាលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពប្រតិបត្តិការ លុះត្រាតែជាតុនោះ ត្រូវបានគេដឹងច្បាស់ថា កើតចេញពីសកម្មភាពហិរញ្ញប្បទាន និងសកម្មភាពវិនិយោគ។

## ៣.៣ ផលប្រយោជន៍នៃការប្រើប្រាស់របាយការណ៍លំហូរសាច់ប្រាក់

### ៣.៣.១ ផលប្រយោជន៍នៃការប្រើប្រាស់របាយការណ៍លំហូរសាច់ប្រាក់

លំហូរសាច់ប្រាក់នៃអង្គភាព មានសារប្រយោជន៍ក្នុងការផ្តល់ឱ្យអ្នកប្រើប្រាស់ របាយការណ៍ហិរញ្ញវត្ថុនូវមូលដ្ឋានសម្រាប់ការវាយតម្លៃនៃលទ្ធភាពរបស់អង្គភាព ក្នុងការបង្កើតសាច់ប្រាក់ និង សាច់ប្រាក់ប្រហាក់ប្រហែល និង សម្រាប់វាយតម្លៃពីតំរូវការប្រើប្រាស់លំហូរសាច់ប្រាក់ទាំងនោះ។ សេចក្តីវិនិច្ឆ័យតាមបែបសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ទាំងឡាយលទ្ធភាពរបស់អង្គភាពមួយក្នុងការបង្កើតសាច់ប្រាក់និងសាច់ប្រាក់ប្រហាក់ប្រហែលហើយនិងការកំណត់ពេលវេលា និង ភាពប្រាកដប្រជានៃការបង្កើតសាច់ប្រាក់របស់អង្គភាពនានា ។

របាយការណ៍លំហូរសាច់ប្រាក់មួយ(នៅពេលដែលវាត្រូវបានប្រើរួមជាមួយរបាយការណ៍ផ្សេងៗទៀតនៃរបាយការណ៍ហិរញ្ញវត្ថុនោះ) ផ្តល់នូវពត៌មានដែលអាចផ្តល់លទ្ធភាពដល់អ្នកប្រើប្រាស់ទាំងឡាយក្នុងការវាយតម្លៃលើបម្រែបម្រួលនៃទ្រព្យសកម្មសុទ្ធនៃអង្គភាពមួយ រចនាសម្ពន្ធ័ហិរញ្ញវត្ថុរបស់អង្គភាព (រួមមាន សន្ទនីយភាព និង សោធនភាព) និងលទ្ធភាពរបស់អង្គភាពក្នុងការជះឥទ្ធិពលលើចំនួនទឹកប្រាក់ និងការកំណត់ពេលវេលានៃលំហូរសាច់ប្រាក់ ដើម្បីធ្វើឱ្យស្របទៅតាមកាលៈទេសៈនិងឱកាស ។ ពត៌មាននៃលំហូរសាច់ប្រាក់នេះមានសារប្រយោជន៍ណាស់ក្នុងការវាយតម្លៃពីលទ្ធភាពរបស់អង្គភាព ដើម្បីបង្កើតសាច់ប្រាក់ និង សាច់ប្រាក់ប្រហាក់ប្រហែលហើយវាក៏មានសារប្រយោជន៍ផងដែរក្នុងការផ្តល់លទ្ធភាពដល់អ្នកប្រើប្រាស់ទាំងឡាយដើម្បីបង្កើតរបៀបវាយតម្លៃនិង ដើម្បីធ្វើការប្រៀបធៀបតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតរបស់អង្គភាពផ្សេងៗគ្នា។ របាយការណ៍នេះក៏ជួយធ្វើឱ្យការប្រៀបធៀបមានភាពប្រសើរឡើងនៃការធ្វើរបាយការណ៍ដោយអង្គភាពផ្សេងៗ ចំពោះការអនុវត្តន៍ប្រតិបត្តិការពីព្រោះវាបានលុបបំបាត់ចោលនូវផលប៉ះពាល់ដោយសារការប្រើប្រាស់ការធ្វើគណនេយ្យកម្មខុសៗគ្នាចំពោះប្រតិបត្តិការ និងព្រឹត្តិការណ៍មួយចំនួនដែលមានលក្ខណៈដូចគ្នា ។

- រចនាសម្ព័ន្ធហិរញ្ញវត្ថុ(រួមមាន its liquidity and solvency)របស់សហគ្រាស។

Liquidity គឺសំដៅដល់ភាពមានប្រាក់បំរុងគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងការដកប្រាក់បញ្ញើនិងកិច្ចសន្យាហិរញ្ញវត្ថុផ្សេងទៀតដល់ពេលត្រូវសង។ (The availability of sufficient funds to meet deposit withdrawals and other financial commitments as they fall due).

Solvency គឺសំដៅដល់ភាពមានប្រាក់សម្រាប់រយៈកាលវែង ដើម្បីឆ្លើយតបទៅនឹង កិច្ចសន្យាហិរញ្ញវត្ថុដល់ពេលត្រូវសងគេ។ the availability of cash over the longer term to meet financial commitments as they fall due.

**៣.៣.២ ការកាត់បន្ថយហានិភ័យផ្ទៃក្នុង**

ការកាត់បន្ថយហានិភ័យផ្ទៃក្នុង (Internal Risk Reduction) ក្នុងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា (Cambodian International Accounting Standards - CIAS) ឬស្តង់ដាផ្សេងៗទាក់ទងនឹងការត្រួតពិនិត្យផ្ទៃក្នុង (Internal Control) គឺមានគោលបំណងធានាថា អង្គភាពអាចសម្រេចបានគោលដៅផ្នែកប្រតិបត្តិការបង្ហាញការស្តារទិន្នន័យហិរញ្ញវត្ថុបានត្រឹមត្រូវនិងគោលបំណងគោលនយោបាយនានា។

ការកាត់បន្ថយហានិភ័យផ្ទៃក្នុងមានផ្នែកសំខាន់ៗដូចជា៖

១. បរិបថនៃការត្រួតពិនិត្យ (Control Environment)ធានាបានពីការគាំទ្រពីថ្នាក់គ្រប់គ្រងគោលនយោបាយនិងនីតិវិធីអាជីវកម្មការចែកចាយភារកិច្ចយ៉ាងច្បាស់។

២. ការវាយតម្លៃហានិភ័យ (Risk Assessment)ការកំណត់និងវាយតម្លៃហានិភ័យអាចប៉ះពាល់ដល់គោលដៅអង្គភាពការរៀបចំយុទ្ធសាស្ត្រការឆ្លើយតបចំពោះហានិភ័យនោះ។

៣. សកម្មភាពត្រួតពិនិត្យ (Control Activities) ការបង្កើតនីតិវិធីត្រួតពិនិត្យ (ex: ការអនុម័តការបញ្ជាក់)ការចែកចាយភារកិច្ច ដើម្បីជៀសវាងការប្រកាន់ចំណាត់ការជាឯកតា។

៤. ព័ត៌មាននិងការប្រាស្រ័យទាក់ទង (Information and Communication)ប្រព័ន្ធព័ត៌មានគាំទ្រការធ្វើសេចក្តីសម្រេចការប្រាស្រ័យព័ត៌មានយ៉ាងមានប្រសិទ្ធភាពក្នុងអង្គភាព

៥. ការត្រួតពិនិត្យនិងតាមដាន (Monitoring Activities)ការតាមដានប្រព័ន្ធត្រួតពិនិត្យជាប្រចាំការត្រួតពិនិត្យជាបណ្តោះអាសន្ន ឬតាមគម្រោងសកម្មភាពទាំងនេះមាននៅក្នុងក្របខណ្ឌ COSO (Committee of Sponsoring Organizations) ដែលត្រូវបានគេយល់ថាជាមូលដ្ឋាននៃការត្រួតពិនិត្យផ្ទៃក្នុងក្នុងស្ថាប័ន ហើយអាចទាក់ទងទៅនឹងការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ (IAS/IFRS)ក្នុងបរិបទកម្ពុជា។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយគឺជា ការវិភាគទៅលើការអភិវឌ្ឍនៃដំណើរការលើរបាយការណ៍លំហូរសាច់ប្រាក់ ដឹងពីការ ការវាយតម្លៃ ការវាស់វែងពីដំណើរការ ការប្រៀបធៀប ការរកចំណុចវិជ្ជមាន និង អវិជ្ជមាននៃសកម្មភាពព្រមទាំងការអនុវត្តន៍នៃស្តង់ដាគណនេយ្យ ចំពោះការធ្វើរបាយការណ៍កន្លងមករបស់ស្ថាប័ននានាដែលអនុវត្តន៍តាមស្តង់ដាគណនេយ្យ។ ក្រោយពីបានសិក្សាពីប្រធានបទសារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧រួចមក យើងខ្ញុំបានពិនិត្យឃើញថាក្នុងការសិក្សាអំពីប្រតិបត្តិការរបស់របាយការណ៍លំហូរសាច់ប្រាក់យើងសង្កេតឃើញថាមានចំណុចខ្លាំងហើយនិងចំណុចខ្សោយមួយចំនួន ប៉ុន្តែការវិភាគចំណុចទាំងនេះវាពិតជាមានសារៈសំខាន់ណាស់ ពីព្រោះបានផ្តល់ភាពងាយស្រួលក្នុងការកែសម្រួលនិងអភិវឌ្ឍន៍ដើម្បីស្ថាប័ននិងក្រុមហ៊ុននានាដែលអនុវត្តន៍តាមស្តង់ដាគណនេយ្យកាន់តែមានភាពរីកចម្រើនទៅមុខ។

## ៤.១. ការវិភាគលើចំណុចខ្លាំង

ចំណុចខ្លាំងនៃរបាយការណ៍លំហូរសាច់ប្រាក់មានច្រើនដែលជាសារសំខាន់សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ច។ ចំណុចខ្លាំងសំខាន់ៗរួមមាន៖

១.ធ្វើអោយប្រសើរឡើងនូវការវិភាគសាច់ប្រាក់ លំហូរសាច់ប្រាក់ គឺជាទិដ្ឋភាពសំខាន់បំផុតមួយនៃអាជីវកម្ម។ ក្រុមហ៊ុនអាចបង្ហាញប្រាក់ចំណេញលើរបាយការណ៍ប្រាក់ចំណូលរបស់ខ្លួនប៉ុន្តែនៅតែប្រឈមមុខនឹងបញ្ហាសាច់ប្រាក់ងាយស្រួល។ សេចក្តីថ្លែងការណ៍លំហូរសាច់ប្រាក់ផ្តល់នូវរូបភាពច្បាស់លាស់នៃភាពអាចរកបានសាច់ប្រាក់ជួយអាជីវកម្មនិងអ្នកវិនិយោគវាយតម្លៃថាតើក្រុមហ៊ុនអាចបំពេញកាតព្វកិច្ចរយៈពេលខ្លីរបស់ខ្លួនដែរឬទេ។ជាឧទាហរណ៍ ក្រុមហ៊ុនផលិតកម្មរបស់ឥណ្ឌាអាចរាយការណ៍ពីប្រាក់ចំណេញខ្ពស់ ប៉ុន្តែប្រសិនបើប្រាក់ចំណូលភាគច្រើនរបស់ខ្លួនត្រូវបានចងភ្ជាប់ជាមួយការទទួលនោះវាអាចប្រឈមនឹងការខ្វះខាតសាច់ប្រាក់។ របាយការណ៍លំហូរសាច់ប្រាក់ជួយកំណត់បញ្ហាបែបនេះជាមុន។

២.ជួយក្នុងការសម្រេចចិត្តអាជីវកម្ម ទាមទារសាច់ប្រាក់សម្រាប់ប្រតិបត្តិការការពង្រីកនិងសកម្មភាពហិរញ្ញវត្ថុ។ សេចក្តីថ្លែងការណ៍លំហូរសាច់ប្រាក់ជួយអ្នកគ្រប់គ្រងធ្វើការសម្រេចចិត្តដែលមានព័ត៌មានអំពីថាតើត្រូវវិនិយោគលើគម្រោងថ្មីទទួលបានទ្រព្យសកម្មឬគ្រប់គ្រងបំណុល។ជាឧទាហរណ៍ ការចាប់ផ្តើមអាជីវកម្មដែលវិភាគលំហូរសាច់ប្រាក់របស់ខ្លួនអាចសម្រេចចិត្តពន្យារពេលការចំណាយមូលធនប្រសិនបើខ្លួនមើលឃើញពីកង្វះខាតសក្តានុពលនៃដើមទុនធ្វើការ។

៣.ការវាយតម្លៃការអនុវត្តកាន់តែប្រសើរ មិនដូចរបាយការណ៍ប្រាក់ចំណូលដែលរួមបញ្ចូលធាតុដែលមិនមែនជាសាច់ប្រាក់ដូចជាការរំលោះ និងរំលោះ របាយការណ៍លំហូរសាច់ប្រាក់ផ្តល់នូវរូបភាពកាន់តែច្បាស់នៃប្រតិបត្តិការហិរញ្ញវត្ថុពិតប្រាកដរបស់ក្រុមហ៊ុន។ វិនិយោគិន និងអ្នកវិភាគប្រើវាដើម្បីវាយតម្លៃថាតើក្រុមហ៊ុនមួយកំពុងបង្កើតសាច់ប្រាក់ពិតប្រាកដពីអាជីវកម្មស្នូលរបស់ខ្លួនដែរឬទេ។ជាឧទាហរណ៍ ក្រុមហ៊ុនដែលរកបានប្រាក់ចំណេញអាចមានលំហូរសាច់ប្រាក់អវិជ្ជមាន ប្រសិនបើវាពង្រីកឥណទានដល់អតិថិជនយ៉ាងខ្លាំងក្លាដែលបង្ហាញពីភាពតានតឹងផ្នែកហិរញ្ញវត្ថុដែលមានសក្តានុពល។

៤.មានប្រយោជន៍សម្រាប់វិនិយោគិននិងម្ចាស់បំណុលភាគីពាក់ព័ន្ធខាងក្រៅដូចជាវិនិយោគិនម្ចាស់បំណុលនិងធនាគារពឹងផ្អែកលើរបាយការណ៍លំហូរសាច់ប្រាក់ដើម្បីកំណត់ថាតើក្រុមហ៊ុនមួយមានស្ថិរភាពហិរញ្ញវត្ថុដែរឬទេ។ លំហូរសាច់ប្រាក់ប្រតិបត្តិការវិជ្ជមានបង្ហាញថាក្រុមហ៊ុនអាចរក្សាប្រតិបត្តិការរបស់ខ្លួនដោយមិនពឹងផ្អែកលើហិរញ្ញប្បទានពីខាងក្រៅ។ជាឧទាហរណ៍ ធនាគារឥណ្ឌាពិចារណាលើការវិភាគលំហូរសាច់ប្រាក់ មុនពេលអនុម័តប្រាក់កម្ចីដល់អាជីវកម្ម។ ក្រុមហ៊ុនដែលមានលំហូរសាច់ប្រាក់វិជ្ជមានជាប់លាប់ទំនងជាទទួលបានមូលនិធិ។

៥.ជួយក្នុងការកំណត់អត្តសញ្ញាណ ការខ្វះខាតសាច់ប្រាក់អត្ថប្រយោជន៍សំខាន់មួយនៃរបាយការណ៍លំហូរសាច់ប្រាក់គឺថាវាជួយឱ្យអាជីវកម្មប្រមើលមើលការខ្វះខាតសាច់ប្រាក់មុនពេលពួកគេក្លាយជារឿងសំខាន់។ នេះអនុញ្ញាតឱ្យក្រុមហ៊ុនចាត់វិធានការកែតម្រូវដូចជាការធានាហិរញ្ញវត្ថុរយៈពេលខ្លីឬកែតម្រូវកាលវិភាគទូទាត់របស់ពួកគេ។

## ៤.២.ការវិភាគចំណុចខ្សោយ

ចំណុចខ្សោយនៃរបាយការណ៍លំហូរសាច់ប្រាក់រួមមានដូចតទៅ៖

១.មិនអើពើប្រតិបត្តិការមិនមែនសាច់ប្រាក់ ការកំណត់សំខាន់នៃរបាយការណ៍លំហូរសាច់ប្រាក់គឺថាវាមិនរាប់បញ្ចូលប្រតិបត្តិការដែលមិនមែនជាសាច់ប្រាក់ ដូចជាការរំលោះ រំលោះ និងការវាយតម្លៃឡើងវិញនៃទ្រព្យសកម្ម។ ធាតុទាំងនេះអាចប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ប៉ុន្តែមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ទេ។ឧទាហរណ៍ ក្រុមហ៊ុនIT របស់ឥណ្ឌា អាចមានការចំណាយមិនមែនសាច់ប្រាក់ខ្ពស់ដោយសារការវិនិយោគលើកម្មសិទ្ធិបញ្ញាដែលនឹងមិនឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ទេ ប៉ុន្តែនឹងប៉ះពាល់ដល់ប្រាក់ចំណេញសរុប។

២.ប្រវត្តិសាស្ត្រនៅក្នុងធម្មជាតិ របាយការណ៍លំហូរសាច់ប្រាក់គឺផ្អែកលើប្រតិបត្តិការកន្លងមកហើយមិនតែងតែផ្តល់នូវទិដ្ឋភាពឆ្ពោះទៅមុខនោះទេ។ ខណៈពេលដែលវាមានប្រយោជន៍សម្រាប់ការវិភាគនិន្នាការ វាមិនចាំបាច់បង្ហាញពីការអនុវត្តនាពេលអនាគតនោះទេ។ឧទាហរណ៍ ក្រុមហ៊ុនដែលមានលំហូរសាច់ប្រាក់ខ្លាំងកាលពីអតីតកាលអាចប្រឈមនឹងការលំបាកប្រសិនបើការលក់នាពេលអនាគតរបស់ខ្លួនធ្លាក់ចុះដោយសារការរំខានទីផ្សារដូចជាការផ្លាស់ប្តូរបទប្បញ្ញត្តិរបស់រដ្ឋាភិបាលជាដើម។

៣. អាចត្រូវបានរៀបចំដូចគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀតដែររបាយការណ៍លំហូរសាច់ប្រាក់អាចត្រូវបានរៀបចំដើម្បីបង្ហាញរូបភាពអំណោយផលបន្ថែមទៀតនៃសាច់ប្រាក់ងាយស្រួលរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនអាចផ្លាស់ប្តូរចំណាត់ថ្នាក់នៃលំហូរសាច់ប្រាក់( ឧទាហរណ៍ ការផ្លាស់ប្តូរសកម្មភាពហិរញ្ញប្បទានទៅជាលំហូរសាច់ប្រាក់ប្រតិបត្តិការ )ដើម្បីបង្កើតការយល់ច្រឡំ។

៤.មិនបង្ហាញពីប្រាក់ចំណេញក្រុមហ៊ុនដែលមានលំហូរសាច់ប្រាក់វិជ្ជមានប្រហែលជាមិនចាំបាច់មានផលចំណេញទេ។ របាយការណ៍លំហូរសាច់ប្រាក់តាមដានតែចលនាសាច់ប្រាក់ប៉ុណ្ណោះនិងមិនរាប់បញ្ចូលប្រាក់ចំណូល និងការចំណាយដែលប៉ះពាល់ដល់ប្រាក់ចំណេញសរុប។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការអធិប្បាយបកស្រាយខាងលើរួចមកក្រុមរបស់យើងខ្ញុំបានយកចិត្តទុកដាក់យ៉ាងខ្លាំង និងខិតខំស្រាវជ្រាវអស់រយៈពេលជាយូជុំវិញខ្លឹមសារនៃប្រធានបទដែលបានលើកឡើងថា សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧ ក្រុមយើងខ្ញុំអាចធ្វើការសន្និដ្ឋានបានថារាល់ខ្លឹមសាដែលបានបកស្រាយមកពិតជាមានលក្ខណៈល្អប្រសើរជាក្រៃលែង។ ហើយរបាយការណ៍លំហូរសាច់ប្រាក់មានការរីកចម្រើនទៅលើវិស័យជាច្រើន ប៉ុន្តែមានវិស័យមួយចំនួនដែលទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំង ពីសាធារណៈជនជាច្រើននៅក្នុងប្រទេសកម្ពុជានោះ គឺវិស័យអប់រំ វិស័យហិរញ្ញវត្ថុ បានរីកដុះដាលយ៉ាងខ្លាំងទៅលើគ្រប់ជំនាញ ។

ម្យ៉ាងវិញទៀតយើងសង្កេតឃើញថា ចំណុចខ្លាំងរបស់របាយការណ៍លំហូរសាច់ប្រាក់ គឺគោលដៅ និងចក្ខុវិស័យ បេសកម្មប្រកបដោយតម្លាភាពស្របតាមសេចក្តីប្រកាសរបស់ស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជាក្នុងការធ្វើឱ្យស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជាមានការរីកចម្រើន និងការអនុវត្តន៍ដែលមានការទទួលស្គាល់ពីរដ្ឋាភិបាលនិងអ្នកវិនិយោគទុនបណ្តាក្រុមហ៊ុនជាច្រើនទូទាំងក្នុងប្រទេស។ នៅពីក្រោយនៃភាពជោគជ័យរីកចម្រើនរបស់ស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧ ដោយសារតែមានការអនុវត្តន៍ដែលបានដាក់ចេញដោយស្តង់ដាមានការរៀបចំគោលនយោបាយយុទ្ធសាស្ត្រផែនការ និងទិសដៅច្បាស់លាស់ និងសំបូរទៅដោយធនធានមនុស្ស នៅក្នុងស្ថាប័នរបស់ខ្លួនពោពេញទៅដោយចំណេះដឹងមានបទពិសោធន៍ មានជំនាញមានសមត្ថភាពនិងជីវៈវិជ្ជាខ្ពស់ ហើយខិតខំព្យាយាមធ្វើការងារ និងមានទំនួលខុសត្រូវខ្ពស់លើការងាររបស់ខ្លួន។ មួយវិញទៀត សព្វថ្ងៃយើងក៏សង្កេតឃើញថា របាយការណ៍លំហូរសាច់ប្រាក់ក៏ជាព័ត៌មានដ៏សំខាន់ដែលប្រាប់នូវស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពនីមួយៗដើម្បីប្រើប្រាស់ជាជំនួយដ៏ល្អប្រសើរបំផុតសម្រាប់ធ្វើសេចក្តីសម្រេចចិត្តស្របទៅតាមបំណងដែលបានគ្រោងទុក។

សរុបសេចក្តីមកឃើញថារបាយការណ៍លំហូរសាច់ប្រាក់ មានសារៈសំខាន់ណាស់ក្នុងការយល់ដឹងកាន់តែច្បាស់លាស់ និងស៊ីជម្រៅពីស្តង់ដាគណនេយ្យព្រមទាំងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ អន្តរជាតិ ស្ថាប័នរដ្ឋ និងឯកជនទាក់ទងនិងហិរញ្ញវត្ថុឱ្យមានភាពងាយស្រួល រីកចម្រើននាពេលបច្ចុប្បន្ននិងនាពេល អនាគត។

## ៥.២ ការផ្តល់អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវអំពី សារៈសំខាន់នៃស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជា៧ រួចមកបានបង្ហាញឃើញថា របាយការណ៍លំហូរសាច់ប្រាក់បានចូលរួមចំណែកក្នុង ការជួយអភិវឌ្ឍសេដ្ឋកិច្ចជាតិនៃប្រទេសកម្ពុជាមានភាពរីកចម្រើន និងបានផ្តល់ការងារជាច្រើនដល់ប្រជាពលរដ្ឋផងដែរ។ ដោយលោកអ្នកបានដឹងរួចមកហើយថា ស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជាបានគេមើលឃើញថាជាក្បាលម៉ាស៊ីនដ៏សំខាន់ដើម្បីជំរុញសេដ្ឋកិច្ច ឆ្ពោះទៅមុខក្លាយទៅជាប្រទេសអភិវឌ្ឍន៍។ ដើម្បីសម្រេចបានសមិទ្ធផលនេះព្រះរាជាណាចក្រកម្ពុជាត្រូវការគណនេយ្យករជំនាញដើម្បីធានាថាសហគមន៍ធុរកិច្ចគោរពតាមបទដ្ឋាន និងបទប្បញ្ញត្តិអន្តរជាតិ។ ដោយសារតែមានហេតុផលបែបនេះហើយទើបធ្វើឱ្យស្ថាប័នរដ្ឋ និងឯកជនមានទំនុកចិត្តក្នុងការ

អនុវត្តន៍ដោយធ្វើឱ្យសេដ្ឋកិច្ចជាតិឈានទៅរកការអភិវឌ្ឍផងដែរ។ ប៉ុន្តែទទឹមនិងនេះស្តង់ដាគណនេយ្យអន្តរជាតិកម្ពុជាក៏នៅតែមានចំណុចខ្វះខាតមួយចំនួនផងដែរ។ ដូច្នេះហើយដើម្បីឱ្យរបាយការណ៍លំហូរសាច់ប្រាក់កាន់តែមានភាពរលូន និងកាន់តែមានភាពប្រសើរ ឡើងថែមទៀតនោះក្រុមនាងខ្ញុំសូមធ្វើការផ្តល់នៅអនុសាសន៍ទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

១.គោរពតាមស្តង់ដា : អង្គភាពគួរតែអនុវត្តស្តង់ដាគណនេយ្យយ៉ាងត្រឹមត្រូវដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុមានគុណភាព។

២. មានភាពស្មោះត្រង់ និងមានតម្លាភាព : អ្នករៀបចំគណនេយ្យគួរអនុវត្តវិជ្ជាជីវៈយ៉ាងស្មោះត្រង់ហើយបង្ហាញព័ត៌មានហិរញ្ញវត្ថុឱ្យបានច្បាស់លាស់។

៣. គាំទ្រដល់ការទទួលស្គាល់អន្តរជាតិ : ការអនុវត្ត CIFRS ធ្វើឱ្យរបាយការណ៍ហិរញ្ញវត្ថុមានស្តង់ដាអន្តរជាតិ អាចបកស្រាយ និងប្រៀបធៀបបានក្នុងទីផ្សារអន្តរជាតិ។

៤. ជួយការវិនិយោគ និងផ្តល់ប្រាក់កម្ចី : ធនាគារ អ្នកវិនិយោគ និងភាគីពាក់ព័ន្ធផ្សេងទៀតអាចប្រើរបាយការណ៍ហិរញ្ញវត្ថុដើម្បីធ្វើការសម្រេចចិត្តលើបំណុល ឬវិនិយោគ។

- បង្កើនតម្លាភាព អ្នកប្រើប្រាស់ទទួលបានព័ត៌មានច្បាស់លាស់អំពីស្ថានភាពហិរញ្ញវត្ថុ។
- ជួយសម្រេចចិត្ត អ្នកវិនិយោគ ធនាគារ អ្នកគ្រប់គ្រង អាចពឹងផ្អែកលើព័ត៌មានដើម្បីសម្រេចចិត្ត។
- ការប្រៀបធៀបបានទូលំទូលាយ អាចប្រៀបធៀបអង្គភាពនៅកម្ពុជាជាមួយអង្គភាពនៅបរទេសបាន។
- ជួយស្របទៅនឹងច្បាប់និងបទបញ្ញត្តិ គាំទ្រការអនុវត្តច្បាប់ពាក់ព័ន្ធ និងការត្រួតពិនិត្យដោយរដ្ឋ។
- ជំរុញភាពជឿជាក់ បង្កើនការជឿជាក់របស់អ្នកពាក់ព័ន្ធលើព័ត៌មានហិរញ្ញវត្ថុ។

# ឯកសារយោង


1. វិទ្យាស្ថាន វ៉ាន់ដា. (2019). *Financial Reporting & Accounting Standard.* បោះពុម្ពលើកទី១១. ភាគ៣ ទំព័រទី៣

2. វិទ្យាស្ថាន វ៉ាន់ដា. (2019). *Financial Reporting & Accounting Standard.* បោះពុម្ពលើកទី១១. ភាគ៣ ទំព័រទី៤-៥

3. Deloitte. IAS Plus. Retrieved February, 17 2025, from https://www.iasplus.com/en/standards/ias

4. Videoslearning. (2023, August 5). *ស្តង់ដារ.* Retrieved February, 17 2025, from https://videoslearning.com/1-2887/

5. KICPAA. គណនេយ្យ. (2023, December 6). *គណនេយ្យ.* Retrieved February, 17 2025, from https://www.facebook.com/100042422426062/posts/1026251348798936/?rdid=zBbsQCE3Fi0TFcfT&_rdc=2&_rdr

6. KHsearch. គណនេយ្យ. (2019, March 26). *គណនេយ្យ.* Retrieved February, 20 2025, from https://www.khsearch.com/qna/17820

7. វិទ្យាស្ថាន វ៉ាន់ដា. (២០១៩). *Intermediate Accounting.* បោះពុម្ពលើកទី១១. ភាគ៣ ទំព័រទី២

8. BIO Accelerator Program. Robert Kiyosak. (2020, July 28). *ទ្រឹស្តីលំហូរសាច់ប្រាក់.* Retrieved February, 20 2025, from https://www.facebook.com/100064424693188/posts/2705208189799843/?rdid=Y7vPaSmEs91AiY2A&_rdc=2&_rdr

9. វិទ្យាស្ថាន វ៉ាន់ដា. (Version2012). *ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា.* ទំព័រទី៣១-៣២

10. វិទ្យាស្ថាន វ៉ាន់ដា. (Version2012). *ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា.* ទំព័រទី ០១៧ - ០១៨

11. IDEA INPUTS. (2025, April 23). *Advantages and Disadvantages of Cash Flow Statement*. Retrieved February, 20 2025, from https://www.indiainputs.com/advantages-and-disadvantages-of-cash-flow-statement/1972/#:~:textរំលងទៅមាតិកា,Candid%20Themes។

# ឧបសម្ព័ន


វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
Intermediate Accounting
VIA.PP/2019


www.vanda.edu.kh


Cambodia International FinancialReporting
Standards (CIFRSs)
Version 2012
Lecturer: A group of professors of Vanda Institute
of Accounting
657.291
Text Book /Y4
VIA.PP/2012


017
Information about the cash flows of an entity is useful in providing users of financial statements with a basis to assess the ability of the entity to generate cash and cash equivalents and the needs of the entity to utilise those cash flows. The economic decisions that are taken by users require an evaluation of the ability of an entity to generate cash and cash equivalents and the timing and certainty of their generation.
The objective of this Standard is to require the provision of information about the historical changes in cash and cash equivalents of an enterprise by means of a cash flow statement which classifies cash flows during the period from operating, investing and financing activities.
1. An entity should prepare a cash flow statement in accordance with the requirements of this Standard and should present it as an integral part of its financial statements for each period for which financial statements are presented.
Benefits of Cash Flow Information
Vanda Institute of Accounting
pecialization of Accounting, Auditing, and Taxation

